# ការសំភាសន៍ជាលើកទី២របស់អ្នកមីងឆេង វី

អ្នកដែលសំភាសន៍ឈ្មោះ ញ៉ែម សុគន្ធា អ្នកដែលត្រូវគេសំភាសន៍ឈ្មោះ ឆេង វី

## ការសង្ខេបរបស់អ្នកមីងឆេង វី

អ្នកមីងឆេង វីមានទីលំនៅក្នុងភូមិដំណាក់សង្កែ ឃុំព្រែកកំពឹស ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

អ្នកមីងឆេង វី

នៅក្នុងការសំភាសន៍នេះអ្នកមីងបានរៀបរាប់ពីជីវិតរបស់អ្នកមីងកាលពេលគាត់បានជួបនឹងស្វាមីរបស់គាត់

គឺស្វាមីរបស់គាត់បានស្រលាញ់គាត់ហើយបានអោយឪពុកមកចូលស្ដីដណ្ដឹងហើយគាត់ក៏បានរៀបការនៅខេត្តកំពត។រៀបការបានកូនប៉ុន្មាននាក់ក្រោយមកក៏ស្វាមីរបស់អ្នកមីងគាត់បានស្លាប់ចោលអ្នកមីង ហើយបន្សល់ទុកនូវកូនហើយគាត់ត្រូវលំបាកដើម្បីមើលកូន ។ពេលប្ដីស្លាប់បានប៉ុន្មានឆ្នាំគឺអ្នកមីងបានយកស្វាមីមួយទៀតដែលគាត់បានរស់នៅជាមួយសព្វថ្ងៃ។អ្នកមីងបានប្រាប់ពីពេលគាត់នៅពីក្មេងគាត់ចូលចិត្តលេងច្រៀងនឹងសំដែងល្ខោន ហើយគាត់ធ្វើបានល្អណាស់ ប៉ុន្តែគាត់អត់ហ៊ានដើម្បីសម្ដែងលើឆាកមែនទែន ។

អ្នកមីងពុំបានរៀនច្រើនឡើយ

ព្រោះតែអត់មានកង់ជិះទៅរៀនហើយសាលារៀននៅឆ្ងាយ។

ក៖ ជាដំបូង

នាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងវីដែលអោយខ្ញុំសម្ភាសអំពីជីវប្រវត្តិរបស់អ្នកវិញម្តងទៀត

នាងខ្ញុំឈ្មោះញ៉ែមសុគន្ធាជាអ្នកសម្ភាសអំពីជីវិតរបស់អ្នកមីងនៅក្នុងថ្ងៃនេះជាលើកទី 2 អ្នកមីងពួកយើងសម្ភាសន៍គឺនៅក្នុងភូមិដំណាក់សង្កែតែគេឥលូវគេដូរមកដាក់ព្រៃកហូវិញហើយ

អញ្ចឹងនៅក្នុងភូមិព្រៃកហូរខាងលិចឃុំព្រៃកហូរក្រុងតាខ្មៅខេត្តកណ្តាលប្រទេសកម្ពុជារឿងសម្ភាសនៅក្នុងថ្ងៃនៅក្នុងខែឧសភាឆ្នាំ 2018អញ្ចឹងនៅខ្ញុំផ្ទាល់ឈ្មោះនាងសុគន្ធាជាអ្នកសម្ភាសន៍នៅក្នុងថ្ងៃនេះអញ្ចឹងកុំប្រាប់ឈ្មោះពេញម្តងទៀតតើឈ្មោះឆេង វី អ្នកមីងមែនទេ?

ខ: ចាំចាំ!!

ក: អ្នកមីងប្រាប់ខ្លួនឯងមើល អ្នកមីងឈ្មោះពេញឈ្មោះអ្វីដែរ មិនបាច់ខ្ញុំនិយាយទេ។

ឆេង រី!!

ខ: ចាំ!!

ក: អញ្ចឹងខ្ញុំនិយាយអោយអ្នកវិញតែម្តងអ្នកមានឈ្មោះឆេង រី។ដោយសារធ្លាប់ស្គាល់នៅដោយសារពេលមុនសម្ភាសអំពីជីវិត របស់អ្នកមីងអញ្ចឹងណាស់!!!

ខ: ចាំ!!

ក: អ្នកមានពេលមុនខ្ញុំបានសួរខ្ញុំអំពីជីវិតរបស់អ្នកគ្រូជាឪពុកម្តាយបងប្អូនអីវ៉ាន់ខ្លះអំពីជីវិតខ្លះខ្លះអំពីក្រុមគ្រួសារហើយប៉ុន្តែនៅកន្លែងដែលអ្នកមិនចង់និយាយបន្ថែមទៀតអ្នកមីងអ្នកមិនអាចប្រាប់ដល់ពួកយើងបន្ថែមទៀតអញ្ចឹងណាស់ដើម្បីទុកឲ្យកូនចៅអ្នកមានជំនាន់ក្រោយស្តាប់ដឹងឮច្រើនអំពីជីវិតរបស់អ្នកមីងទោះដឹងថារាប់រយរាប់ពាន់ឆ្នាំអញ្ចឹងទៅគឺវានៅតែរក្សាទុកច្រើនអញ្ចឹងទៅអ្នកមីងណាស់!!!

ខ: ចាំ!!

ក: អញ្ចឹងអ្នកមីងសម្រាប់អ្នកវិញអ្នកមិនរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ខ: ខ្ញុំមិនដែលរៀនផង។

ក: ចឹបានជាអត់រៀមៗចឹងអ្នកវិញវិលមកពីមូលហេតុអ្វីបានជា អញ្ចឹង?

ខ: ខ្ញុំបានចូលដល់ថ្នាក់ទី 1 ប៉ុន្តែដល់ពេលហើយម្តាយរបស់ខ្ញុំថាអោយទៅតាមម្តាយរបស់ខ្ញុំដូចថាឲ្យទៅធ្វើដីស្រែអញ្ចឹងណាស់ម្តាយរបស់ខ្ញុំនៅភ្នំពេញខ្ញុំចូលទាំងអស់គ្នាបងប្អូនខ្ញុំចូលដល់ពេលហើយចូលដល់ថ្នាក់ទី 1ដល់ពេលហើយ រៀនបានពីរបីថ្ងៃម្តាយរបស់ខ្ញុំយកកូនទៅខាងណោះដល់ពេលហើយប្រាប់ប្តីគាត់ថាឲ្យកូនចៅនៅទីនោះទៅរៀនអញ្ចឹងបានអ្នកណាចិញ្ចឹមវាទៅបើយើងនៅឯណោះនិង!!!ដល់តែយូទៅភ្នំពេញនៅតែនៅភ្នំពេញអោយទៅរៀនសាលាជើ

ងគោកសាលាមួយរយខ្នងនោះណាស់!!ក៖ហ្អឺ!!ខ៖ទៅរៀននៅសាលាមួយរយខ្នងនោះណាស់។

ក: អានិងសាលា 100 ខ្នងនិងដូចនៅភ្នំពេញថ្មី អ្នកមីងមែនទេឥឡូវ?

ខ: នៅភ្នំពេញទៅនៅភ្នំពេញដល់ពេលចុះឈ្មោះហើយកូនចៅកូនគាត់ពីកូនគាត់ពីកូនចុងណឹង ពីរនាក់ហើយកូនម្តាយរបស់ខ្ញុំនេះបីនាក់3 នាក់ដល់តែហើយទៅទៅទៅអត់បានចូលចូលបានពីរនាក់ដែរភ្នំពីរដែរឯណោះ 3ឯណោះ 2 ទាំងអស់ 5 នាក់!!ចុះឈ្មោះចុះអីហើយស្រាប់តែហើយគេអោយគ្រូខ្ញុំម៉ែខ្ញុំថាអញ្ចេកនិយាយជាមួយគ្នាគ្នាឯង និយាយជាមួយនឹងកូនគាត់ហើយនិងបងរបស់ខ្ញុំនឹងណាស់ហើយប្អូនខ្ញុំថាអញ្ចេក ហ៊ឺអញខ្ជិលណាស់នៅឆ្ងាយដែលផ្ទះនៅ 100 ខ្នងហើយដើរទៅរៀនដល់សាលាហើយផ្ទះនៅទួលគោកហើយទៅរៀនដល់សាលាមួយរយខ្នងឯណោះ!!

ក: អូយ!! ឆ្ងាយណាស់!!ឆ្ងាយណាស់អ្នកមីងណាស់?

ខ: ឆ្ងាយឆ្ងាយខ្ញុំថាអញចេះឆ្ងាយដល់ហើយអត់មានកង់ៗចឹងៗអញសុំកង់ម៉ែមួយសំកង់ហើយ ៗទាល់តែបានកង់អញបានទៅរៀន ដល់តែអាមួយថាអញ្ចេកមានកង់បានអញទៅរៀន ហើយប្អូនខ្ញុំថាអញ្ចេកមានកង់បានទៅរៀនដល់មួយថាអញ្ចឹង អញបើអត់មានកង់អញអត់ទៅទេនិងចុះឈ្មោះហើយហើយថាអញ្ចឹង តែអត់មានកង់អត់ទៅទេ!! ដប់ស្អែកឡើងម្ដាយរបស់ខ្ញុំថាពួកហ្នឹងអត់ទៅរៀនទេហេ?អាវីថាទាល់តែមានកង់បានវាទៅរៀន!!គេថាអត់ចង់វាអត់ទៅរៀនទេខ្ញុំអត់ទៅដែរអាមួយថាអត់ទៅអាមួយថាអត់ទៅអត់ទៅទាំងអស់គ្នាទៅ!!

ក: អញ្ចឹងអត់មានអ្នកណាបានទៅរៀន?

ខ: អត់មានអ្នកណាបានទៅរៀនអត់បានទេរៀនទាំងអស់គ្នា!!!

ក: ហើយត្រូវចុះឈ្មោះចូលរៀនថ្នាក់ទី 1ហ្នឹង?

ខ: ទី 1

អត់បានចូលរៀនតែបានពីពេលមុនមុនគេបានចូលរៀនខ្លះណាស់តែខ្ញុំមិនបានចូលរៀនតែម្តងពួកគេមុនមុនបានគេចូលរៀនហើយបានគេចេះខ្លះខ្ញុំអត់ចេះខ្ញុំអត់ចេះសរសេរតែខ្ញុំអត់ចេះអានតែខ្ញុំចេះសរសេរ។

ក: អ្នកមីងចេះសរសេរ?

ខ: ចាខ្ញុំចេះសរសេរ។អក្សរខ្ញុំស្អាតណាស់។

ក: ចេះសរសេរមកពីណា?

ខ:

ខ្ញុំចេះសរសេរប៉ុន្តែខ្ញុំមិនចេះអានមិនចេះអានមើលមិនរួចទេ!!ថាបើសរសេរខ្ញុំចឹះទាំងអស់

បើល្ខោនខ្ញុំចេះខ្ញុំចាំហើយណារឿងល្ខោនច្រៀងអីដូចតែខ្ញុំខ្ញុំប្រាប់អូនឯងល្ខោនលេងនៅភូមិ ដំណាក់សង្កែគេលេងល្ខោន គេរាំរោងឲ្យតែថ្ងៃសីលថ្ងៃសីល ដល់ពេលហើយគេចាប់ផ្តើមជួលលេខឡាននៅណាគេជួលទៅខ្ញុំទៅមើលល្ខោនមើលខ្ញុំអា ចច្រៀងបានអីបានខ្ញុំពីក្មេងទៅរៀនមកពីរៀនដាក់កង់ចុះដាក់ខោអាវដាក់កាបូបព្យួរថាក់ក ង់ទៅផ្សារតាខ្មៅទិញ!!

ក: ទិញស៊ីគេ?

ខ: ទិញអង្កាំ។

ក: ទិញអង្កាំ?

ខ: ទិញយកមកលេងធ្វើខ្សាក់ធ្វើអី ទុកសម្រាប់លេងល្ខោន!! ក៖ហ្អ៎!!ខ៖ហើយផាមួង របស់ខ្ញុំ ម្តាយរបស់ខ្ញុំ កាត់ផាមួង ហើយនិងអាវប៉ាក់ ខ្ញុំកាត់ខោអាវដេកប៉ាកលេងល្ខោនលេងអី

ខ្ញុំគឺជាអ្នកបង្ហាត់ល្ខោនគេមេល្ខោនតែខ្ញុំចេះតែបង្ហាត់ក្មេងៗគ្នាឯងអាពួកនិងយូយូអត់ចេះអក្សរពីចាស់លេងល្ខោន។

ក: អញ្ចឹងអ្នកមីងចង់លេងនៅ ល្ខោនវិញមែនទេពេលក្មេងៗលេងធ្វើល្ខោនអញ្ចឹងទៅអ្នកមីងណោះ?

ខ:

ហ្នឹងហើយក្មេងៗនែឯងហាត់ល្ខោនរៀនច្រៀងអត់ដល់ពេលហើយខ្ញុំបង្ហាត់ពួកវាឲ្យរៀនច្រៀងដោយហើយខ្ញុំថាអញ្ចេក

ពួកទាំងអស់នឹងចេះច្រៀងហើយចេះហើយឥឡូវអាចទៅលេងនៅលើថ្នល់ជាមួយនឹងអញអត់ទៅលេងនៅលើថ្នល់កន្លែងផ្ទះគេនេះថ្នល់នេះមានដើមអំពិលបារាំងមួយហើយមានសាខាធំណាស់ហើយមានគ្រែនំបញ្ចុកគេនំបញ្ចុកគេត្រឹមចង្កេះគ្រែធំដែលជ័យលក់នំបញ្ចុកគេឈប់លក់ខ្ញុំយកបាំង

ខ្ញុំយកបានតែល្បងគេមានតែជញ្ជាំងជញ្ជាំងទេអត់មានរោងអត់មានអញ្ចឹងអីខ្ញុំយកវាំងននមកបាំងអីតាំងអញ្ចឹងទុកតែប្រហើយដំបូលអាដំបូលចំហផ្លុង

ខ្ញុំធ្វើខ្លួនធ្វើអីហើយអញ្ចឹងឥឡូវឯងពួកនឹងហ៊ានចេញមកច្រៀងដែរឬទេតាមផ្ទល់ប្រយ័ត្នគេមើលណាស់អត់ទេស្ម័គ្រចិត្តហ៊ានអាមួយថាស្ម័គ្រចិត្តហ៊ានឥឡូវច្រៀងអញ្ចឹងទៅហើយខ្ញុំដាក់អានេះតួអ្វីអានេះតួរងអានេះតួឯកតួអីអញ្ចឹងទៅទូលកូនអីអញ្ចឹងទៅហើយចាប់ដៃចេញមក!! អូនអើយយប់ឡើងម៉ោងបួនម៉ោង 5និង6 ចាប់ផ្ដើមគេលេងនៅផ្ទល់រម៉កឡានឈប់មើលគ្រប់គ្នា ហើយគេឆ្ងល់ថាអញ្ចេកក្មេងក្មេងប៉ុណ្ណឹងចេះច្រៀងល្ខោនមួយណាមេល្ខោន?

ក: ហ៊ីហ៊ានទៀត??

ខ: ហើយគេសួរមួយណាមើល ល្ខោនហើយខ្ញុំថាហើយយ៉ាងម៉េចចាំសួររកមុខល្ខោនចាំអង្គុយមើលកូនល្ខោនអង្គុយនៅខាងមុខ ចេះឬក៏មិនចេះអញ្ចឹងទៅខ្ញុំប្រាប់ ។

ក: អ្នកមិនមានដុងខាងសិល្បៈ!!

ខ: ខ្ញុំល្បី ខ្ញុំល្បីខាងរឿងអញ្ចឹងអញ្ចឹងណាស់ ហើយខ្ញុំប្រាប់ថាខាងរបាំខ្ញុំពូកែខាងលើងពូកែខាងរាំបើអញ្ចឹងទេតឡូវឈប់លេងហើយខ្ញុំផ្អាកលេងល្ខោនខ្ញុំលេងការ

ហេតុការណ៍ក្មេងទើបតែកំពស់កំពស់នេះធំធំដែលនឹងណាស់ទឹមដប់ប្រាំបីឆ្នាំ 18ឆ្នាំ7 ឆ្នាំ 8ឆ្នាំនិងណាស់ លេងល្ខោនកាត់ខោអាវកាត់អ្វីៗចឹងណាស់ អូនអើយទៅដីអង្កាំទៅដេររអីកាត់អាវកាត់អី ចាប់សំពត់ចងក្បិនទិញទ្រ ទិញទ្រគេគេដាក់លក់ទ្រ ដាក់អីដាក់ជាងគេដើរលក់ទ្រ ស្គរគេឃើញស្គរគេទិញស្គរទិញទ្រខ្ញុំណាស់នាំគ្នាលេងហែរទាំងពីរថ្នល់ទៀតឯណោះ ។

ក: ចំខ្លាំងបាត់!!!

ខ: ខ្ញុំនិយាយត្រង់ណាថាអក្សរខ្ញុំអត់ចេះចេះតែល្ខោនអាភ្លេងការ ឡើងខូចមុខខូចមាត់អស់រលីង

លេងល្បែងៗចឹងៗចឹងក្មេងៗថារីលេងអញ្ចឹងអញ្ចឹងក្មេងៗកូនៗអត់មានអ្នកណាចេះអក្សរទេ វាលែងតែល្ខោនលេងតែអី លេងតែភ្លេងការ លេងការលេងឲ្យអស់រលីង

ការមានស្រីមានប្រុសអញ្ចឹងមានកម្រងផ្កាមានអីមានអីអញ្ចឹងដូចជាខោអាវខ្វាសេ

ស្រីស្លៀកសំពត់ចងក្បិន ស្បែកជើងកែង!!

ក:

ហើយបានខោអាវទាំងអស់ហ្នឹងមកពីណា?ខ៖ចាំ?ក៖បានខោអាវទាំងអស់ហ្នឹងមកពីណា?

ខ: ថា យ៉ាងម៉េច?

ក: ខោអាវដែលអ្នកនឹងកាត់ខ្វាសេរបានមកពីណា?

ខ: កាត់។

ក: ពីណា?

ខ: កាត់អញ្ចឹងទិញខោអាវខ្វាសេ

ធម្មតាយើងទិញអីដាក់ពាក់ជាធម្មតានិងណាស់!!!ក៖ហ្ហ៎!!!ខ៖ហើយដល់ហើយបានអញ្ចេ

កហៅថាអញ្ចាកដល់ពេលកូតទ្រូថហែរតាមផ្លូវថ្នល់ហើយដល់ពេលទ្រុងគោបន្ទប់គេគឺទ្រុងគោទ្រុងគោខ្ញុំនឹងណាស់!!ដៃគូរបស់ខ្ញុំនឹងណាស់!! how ទ្រុងគោរបស់ខ្ញុំមាន 2 នៅទីនេះមួយនៅទីនោះមួយខាងនេះខាងប្រុសខាងនោះខាងស្រី!!

ក: ងាប់ហើយ!!!

ខ: លេងតែអញ្ចឹងខ្ញុំ!!

ក: នៅពីក្មេង!!ហ្នឹងហើយវក់លេងពេកអប់រំទៅសាលា!!

ខ: ហ្នឹងហើយបានអត់ចេះអក្សរ។

ក: នាំក្មេងៗកូនចៅគេជិតផ្ទះលេងដែរ!!

ខ: ក្មេងគ្នាឯងប៉ុនប៉ុនគ្នាឯងហ្នឹង កាន់តែតូចតូច 12ឆ្នាំ 13 ឆ្នាំនឹងណាស់ហើយអញ្ចឹងវក់លេងអញ្ចឹងបានយូរយូរអត់ចេះអក្សរពីព្រោះតែអានឹងបានថាអញ្ចឹងល្ខោនខ្ញុំចេះណាស់ហើយមាន 2នាក់ស្រីៗគ្នាខ្ញុំដើរតាំងពីអាយុ 12 ឆ្នាំធំដែរសក់ឡើងត្រឹមចង្កេះនិងហើយពួកម៉ាកខ្ញុំផ្ទះនៅទីនេះ!! ដល់ហើយឃើញគេបង្ហាត់ល្ខោនបង្ហាញល្ខោនស្ដាប់តែឯងឃើញហើយទៅលេងនៅឯណា!!! ហើយរត់ទៅផ្ទះពូបានពូបានលេងល្ខោននេះ គេបង្ហាត់ល្ខោនហើយក៏រត់ទៅលោតទៅស្រាប់តែពូពូ ខ្ញុំឮអ្នកណាគេច្រៀងល្ខោនស្មានតែគេលេងល្ខោនឯណាកុំទៅមានឯណាអញឃើញពួកនិងច្រៀងលេងនឹងហ៎ !!! ហើយចេះតែដំ ទៅដល់ពេលហើយ ច្រៀងមួយបទសិនមើលទៅខ្វះអីអញ្ចេះៗអី មិនមែនអត់ចេះទេដាក់តែឥឡូវហ្នឹងគ្រាន់តែអត់ចង់លេងទេតើតាអញ្ចិងដល់ពេលហើយអូនអើយគេរត់មើលគ្រប់គ្នាល្ខោនណាស់ខ្ញុំច្រៀងទៅឡើងផ្អើលណាផ្អើលនៃរត់មក!!! ហើយ ល្ខោនមកពីណា?? អាវីចេះតែច្រៀងលេងនឹងណាស់!!ឡើងច្រៀងលេងអោយគេផ្អើល ឥឡូវៗដាក់អោយអាវីច្រៀងលេងពីរផ្អើលគ្រប់គ្នាហើយចង់យប់ថ្ងៃហ្នឹងថ្ងៃសីលគេហាត់ល្ខោនជួលទៅលេងឯណានោះ ហើយសក់ខ្ញុំត្រឹមហ្នឹង

ហើយស្អែកឡើងមេល្ខោននឹងណាស់មីងរៀមនិងមេល្ខោនអញ្ចេកមកសួរម្តាយខ្ញុំបងបងខ្ញុំ សុំអោយអារី ទៅលេងល្ខោនដែលកូនអោយឲ្យវាលេងដែរឬអត់? ទេវាចេះដែងណាវា?ហ៊ីអត់ចេះឯណា អារីច្រៀងល្ខោននៅផ្ទះពូបាន សំលេងខាងឆ្វេក គឺឡើងផ្អើលមកមើលគ្រប់គ្នាហើយខ្ញុំសុំវាហើយទៅព្រោះអត់មានតួឥឡូវខ្វះតួរ ខ្ញុំសមអោយអារីនឹងទៅជាមួយនឹង ហើយសក់ត្រឹមត្រឹមចង្កេះ ហើយវាសក់វែងអញ្ចឹងវាដើរតួរកូនចុះស្រួលក្រវីសក់អញ្ចិងហិ!!!

ក: ឡូយបាត់!!

ខ: ហើយម្តាយរបស់ខ្ញុំថាអញ្ចេក ហេ!!សុំអីៗវិញទៅសួរម្ចាស់ខ្លួនគេ ហើយដល់ហើយ ម្ចាស់ខ្លួនគេឲ្យទៅអញ្ចឹងឲ្យទៅដែរ អញ្ចឹងហិបានម៉ែខ្ញុំថាអញចឹងបានហើយស្អែកឡើងគាត់មកសួរ ហាពេលថ្ងៃឡើងហូបបាយហើយគាត់មកហើយអារីអារី មកអញ្ចេះមក ៗសុំសួរថារីឯងអារីឯងលេងល្ខោនមួយអី? អញ្ចហើយដើរតួរកូន ដើរតួរកូនអត់ពិបាកទេ!!អត់មានដើរវែតប់អ្វីទេ!! ចាំ

យើអត់មានអ្នកណាគេរ៉េទៅប៉ុន្តែចុងក្រោយគេធ្វើបាប ខ្ញុំថាអញ្ចេក ខ្ញុំអត់លេងទេ ខ្ញុំឃើញល្បែនគេលេងរាល់ថ្ងៃគេរ៉េតប់ ជេរ គប់នឹងដុំថ្មដុំអីធ្វើបាប។

ក: ចា អញ្ចឹងអ្នកមីងអត់បានចូល ហាត់ក្រុមល្ខោនធំដូចជាគេឯណាមែនទេ?

ខ: អត់ទេ។

ក: គេហៅទៅដែរប៉ុន្តែអត់ទៅអត់ទៅ។

ខ: អត់ចូលហើយខ្ញុំថាអញ្ចេកទៅសុំអង្វរសុំអង្វរទៅៗអោយមួយយប់ ថាលេងចូលទៅមួយយប់ៗអោយឯង 50000 ទៅៗអោយថ្លៃជាងគេដើរតួរកូន ដើរតួរកូនបានថ្លៃណាស់ទេខ្ញុំខ្លាចគេធ្វើបាបខ្ញុំត្របកភ្នែកទន់ខ្ញុំយំងាប់តែឥឡូវហ្នឹង
ខ្ញុំមិនទៅមើលល្ខោនគេឯណាខ្ញុំដើរតួកាចម៉ែខ្ញុំជេរខ្ញុំអីនោះ!!
ហើយអោយខ្ញុំទៅលេងទៀតខ្ញុំខ្លាចគេធ្វើបាបខ្ញុំណាស់ខ្លាចគេម៉ី!!

ក:                    ភ្នែកទន់ទៀតមីងណោះ?អញ្ចឹងអត់បានចូលរៀនទេទៅលេងល្បែន

ក្មេងៗគ្នាឯងគេឲ្យទៅដែរប៉ុន្តែអត់ព្រមទៅទៀត!!

ខ: ខ្លួនឯងដើរបង្អាត់គេលេងល្បែនដល់ពេលខ្លួនឯងអត់ទៅទៀត អត់ទៅទេ។

ក: ហើយថៃបានមិនព្រមទៅ កុំអីធ្វើតួល្ខោនទល់តែ ចំណាស់និងទៀតមិនស្រួលហិ!!!ចា

អ្នកមានក្ដីស្រមៃធំឡើងពីក្មេងចង់ធ្វើអ្វីដែលឬក៏អត់?

ខ: ខ្ញុំនៅពីក្មេងខ្ញុំមិនដែលធ្វើអ្វីទេខ្ញុំស្រណុក រហូតណាស់!!

ក:

ដឹងហើយប៉ុន្តែធំឡើងមានដែលគិតថាចង់ធ្វើជាអ្វីមួយដែលរឺទេ?អត់ដែលគិតមួយនឹងទេមែ

នទេ?

ខ: អត់ទេអត់ដែលទេ!!!

ក:

តែទោះជាយ៉ាងម៉េចបើស្រឡាញ់ខាងសិល្បៈមិនព្រមធ្វើតួល្ខោនទៅអត់ទេ!!!ទៅគេហៅមិនព្រមទៅ!!

ខ: នេះខ្ញុំទៅនៅ អ៊ីទួល គោក ស្អីពោចិនតុងនេះ!! ខ្ញុំឃើញគេហាត់សិល្បៈខ្ញុំថាចង់រាំនឹងគេ ស្រាប់តែបងមួយនោះថាអូនឯងចេះចង់រាំរបាំអញ្ជើង ខ្ញុំចេះទេតើរាំរបាំខ្ញុំគ្រាន់តែឃើញខ្ញុំអាចចេះធ្វើបានខ្ញុំគ្រាន់តែមើលមួយភ្លែតខ្ញុំអាចចេញទៅបានខ្ញុំរាំរបាំបានអញ្ជើងចូលទៅ ខ្ញុំអត់ហ៊ានចូលទេព្រោះអ៊ីម្តាយឪពុករបស់ខ្ញុំនៅភ្នំពេញហើយខ្ញុំគ្រាន់តែមកតាមបងរបស់ខ្ញុំមកលេង ម្តងម្កាល ហៅខ្ញុំចូលលេងយ៉ាងម៉េចទៅអញ្ជើងណាស់ហើយខ្ញុំពូកែរាំរបាំឃើញគេរាំរបាំខ្ញុំចេះអាចចេះច្រៀងបានតែរាំបានតែអត់លេង អត់ហ៊ាន!! ចូលមួយចូលមួយតែមិនព្រមចូល ។

ក:

ឥឡូវចេះច្រៀងបទអីដែរទេច្រៀងមួយបទឲ្យស្ដាប់បន្តិចមើល?មើលពីរោះប៉ុណ្ណាទៅដល់ថ្នាក់ឲ្យអ្នកភូមិនេះ!!!ឥឡូវច្រៀងល្ខោនមួយមើល!!

ខ:អត់ទេ!!

ក: ធ្វើឯងអូសក្រឡាអីណាទៀត!!!

ខ: ភ្លេចអស់ហើយការពេលនៅទី តូចតូចពូតែឥឡូវចង់ភ្លេចអស់ហើយពេលចាស់បន្តិចចាស់បន្តិចចង់ភ្លេចអស់ហើយចង់ភ្លេច!!

ក: ហ្អ ៗចឹងឥឡូវភ្លេចអស់ហើយអ្នកមិនមែនទេ?

ខ:

បើបានគេច្រៀងគេច្រៀងបានមើលល្ខោនគេច្រៀងទៅបានចេះឥលូវទៅមើលល្ខោនរាល់ថ្ងៃអញ្ចឹងនេះ ងាប់ហើយល្ខោនច្រៀងចាញ់អញទៀតនោះ

ឥឡូវភ្លេចអស់ហើយនៅពេលក្មេងៗចាស់ឥឡូវដល់ពេលខ្លួនឯងកាន់តែចាស់ទៅចង់ភ្លេចអស់ហើយ!! អញ្ចឹងបានថាលេងតែពីក្មេង។ក៖ចា៎!! ខ៖ ដល់ពេលយូរយូរចង់ភ្លេចអក្សរអស់រលីង ចេះលេងតែរឿងអញ្ចឹងអញ្ចឹងបានជាអញ្ចឹង!! អញ្ចឹងបានគេថាអ្នករៀនចេះរបាំមកពីភ្លៅ ភ្លៅ របស់ខ្ញុំមានប្រជ្រុយសងខាង!!!

ក: ប្រជ្រុយហេ?

ខ: ចា៎!! មើលតែខ្ញុំនេះកន្លែងនេះប្រជ្រុយ 1 កន្លែងមួយនេះមានប្រជ្រុយ 1។

ក: ៗចឹងបានខ្ញុំគ្មានប្រជ្រុយ អញ្ចឹងបានជាខ្ញុំអត់បានចូលរួមនឹងគេតែស្រលាញ់ណាស់សិល្បៈនោះ!!

ខ: ហ្នឹងហើយដូចថាប៉ុនរាំរបាំអញ្ចឹង ប្រជ្រុយនៅភ្លៅ ប្រជ្រុយសងខាងនិងប៉ុនរាំរបាំមែនដល់ពេលខ្ញុំលាត់ភ្លៅ ខ្លួនឯងមើលមានប្រជ្រុយទាំងសង្ខាងជើងភ្លៅ!!!

ក: ចាអ្នកមិនអញ្ជើងចូលដល់ប្ដីវិញម្ដងធ្មេញប្ដីដំបូង  រៀបការមឹងពេលមុនប្រាប់ខ្ញុំថាមាន

សាមីពីរមែនទេអ្នកមឹង?

ខ: ស្អីគេ?

ក: ស្វាមីប្ដីរបស់អ្នកមឹងណាស់?

ខ: អត់ដែលធ្វើបាបទេបើសិនជាខ្ញុំនិយាយអញ្ចេះ!!!

ក: ហ្អ៎ ឈប់ឈប់ឈប់ កុំទាន់អាលនេះប្ដីទី 1 ឈ្មោះអ្វី?រៀបការដំបូងស្អីគេពេលម៉ែចង់

ឲ្យកាលពីពេលនោះ?

ខ: ថា!!

ក: ឈ្មោះថា?

ខ: ចាំ!!

ក: អីគេថាចាំត្រកូលរបស់ប្តីទេ? ដូចអ្នកមីងឈ្មោះឆេង រី!!!

ខ: ឪពុករបស់គាត់ឈ្មោះ ងើយ ងើយ វុត្ថា ។

ក: ហើយ វុត្ថា?

ខ: ចាំ!!!

ក: ការជាមួយលោកពូនៅឆ្នាំណា?

ខ: ចាំ?

ក: ការជាមួយលោកពូនៅឆ្នាំណានៅឆ្នាំណាលោកពូថានឹងណាស់??

ខ: ហើយថី?

ក: ការយូរហើយឬនៅ?

ខ: នៅកាយូរហើយការនៅកំពត ការដូចកាលពេលខ្ញុំនិយាយថាទើបតែបែកលន់ នល់ហ្នឹង!!!

ក: អ្នកមីងបាននិយាយពីថ្ងៃមុនដែរ!!!ok បែក លន់ណុលហើយ!!បែកលន់នល់ចូលប៉ុលពតហៅអ្នកមីង??

ខ: ចានឹងបែកលន់ នល់ហើយដូចថាយើងនៅស្រុកស្រួលបួលហើយអញ្ចឹង!!

ក: ហ្ន៎ អញ្ចឹងបែក លន់ណុល ផងប៉ុលពតផងបានរៀបការមែនទេ?

ខ: ចាចាំ,!!

ក: ហើយ ពេលនឹងប្ដី!!

ខ: កាលពេលនិងមិនទាន់មានអ្វីផងនូវការស្រុកកំពតទៅការស្រុកកំពតគ្មានមិនទាន់មានបាសមានអីណា!! មានតែស្គរសាខេ ហ្នឹង ហើយមានទ្រ ហើយនិងស្គរសាខេហ្នឹង?!!ខ្ញុំទៅតែនៅស្រុកកំពតបើសិនជាការស្រុកយើងខ្ញុំមានហើយយើងភូមិណាភូមិណាក៏មិនទាន់មានបានដែរទើបតែឥឡូវឥឡូវពេលនេះបានមានឥឡូវ មានអកកេះ អកកាដង់!! ពេលនិងគ្មានអ្វីទេ!!

ក: ពេលមុនទើបតែបែកមកវាយគ្មានអាអញ្ចឹងៗទេអ្នកមីងណោះ?ខៈចាំ!!កៈចាំ!! ឥឡូវប្ដី

អ្នកមីងលោកពូរុត្តាគាត់ស្លាប់ ឬក៏គាត់រស់?

ខ: កូនស្លាប់ស្លាប់យូរហើយថាខ្ញុំទើបតែមកពីស្រុកកំពតកោះស្លាប់ហើយនៅកំពតនិងខ្ញុំបានកូន 3នាក់ 4នាក់ហើយបានគាត់ស្លាប់នោះ!!!ពុទ្ធស្លាប់និង!!

ក: មូលហេតុអ្វីបានជាគាត់ស្លាប់នឹងអ្នកមីង?

ខ: កាលពេលគាត់ស្លាប់និងកូនខ្ញុំ មីមួយពៅគេសព្វថ្ងៃហ្នឹងតូចណាស់ទើបតែប្រហែលអាយុប៉ុន្មានឆ្នាំនិងអត់ទាន់ចេះនិយាយ ទឹមតែចេះដើរទេសតាសនឹង ហ្នឹងហើយប្តីរបស់ខ្ញុំស្លាប់ ចាំ!!

ក: គាត់ស្លាប់គាត់ឈឺឬក៏គាត់ធ្វើអី?

ខ: គាត់ថ្ងៃនឹងគាត់និយាយអញ្ចេក យ៉ាងម៉េចបានជានិយាយពាក្យអញ្ចឹងចាំមើលនៅផ្ទះកូន 3 នាក់នៅផ្ទះហ្នឹងហើយដល់ពេលថ្ងៃនឹងគាត់ធ្វើការការដល់ផ្សារបឹងកេងកងណាស់គាត់ធ្វើការនៅភ្នំពេញគឺការសំណង់ដល់ពេលថ្ងៃនឹងគាត់នៅផ្ទះគាត់មិនម្ហូប ស៊ីគាត់ថាអញ្ចេកម៉ោងប្រាំហើយ ហ៊ីឯងតោសយកសំណាញ់មកអញទៅបង់ត្រី ទៅខាងក្រោយដូច

នេះផ្ទះខ្ញុំនៅរាល់ថ្ងៃនេះ ដើរតាមភ្លឺស្រែអញ្ចឹងទៅមានស្រះគេមួយណាស់មានស្រះមួយមានត្រីណាស់គ្រាន់តែថាអញ្ចេក ឯងយកសំណាញ់មកការយកទៅបង់ត្រី ឯងអើយម៉ោងប្រាំហើយមិនបាច់ទៅបង់ត្រីឯណាទេយប់ហើយ ទម្រាំតែមកវិញស្មើម៉ានទំរាំតែបានធ្វើស៊ីទេ តោះឯងឥឡូវខ្ញុំទៅខ្ចីលុយបងរបស់ខ្ញុំ ខ្ញុំថាខ្ញុំខ្ចីលុយរបស់បង 3000ទិញម្ហូបស៊ី ឯងមិនបាច់ទេនាំតែជំពាក់គេទេទៅយកសំណាញ់អោយអញមក ៗទៅបងដល់ហើយតាអញ្ចឹងដល់ហើយខ្ញុំយកសំណាញ់ទៅឱ្យគាត់គាត់កូនរបស់ខ្ញុំមីមួយពីរនិងមីមួយទី៤ អាយុប្រហែលទើបតែ 6 7 ឆ្នាំទេដល់តែពេលហើយដើរទៅកាន់ធុងទៅដល់ពេលកាន់ធ៊មទៅប្ដីរបស់ខ្ញុំលីសំណាញ់ទៅៗ គ្រន់តែដំបូងអូនអើយអូនគ្រាន់តែបងភ្លាមបានត្រីភ្លាម គាត់ថាអញ្ចេក ខ្ញុំបង់ត្រីតែមួយសំណាញ់ទេមួយសំណាញ់អញយកតែត្រីកន្ទ្រប់1ត្រីផ្ទក់ 1និងកង្កែប 1ទៅមួយសំណាញ់បានមែនបានតែ 3 និងមែនបានតែបីយកមកភ្លាមយកមកភ្លាមដើរតាមផ្ទះគេតាមផ្ទះគេនឹងជាប់ផ្ទះខ្ញុំនឹង ហើយផ្ទះគេមានដើមចេកហើយត្រយូងធ្លាក់យូៗ បកធ្លាក់អស់ហើយសល់តែទូចទេតាំងពីធំរហូតដល់តែប៉ុនេះដល់ហើយគេថាឯងមានកង្កែបចង់ស្ងោរត្រយ៉ូងចេកឆ្ងាញ់ណាស់ ខ្ញុំថាអញចឹងមែនកង្កែបស្ងោរត្រយ៉ូងចេកឆ្ងាញ់ណាស់ដល់ពេលហើយចុះឯងកង្កែបស្ងោរត្រយ៉ូងចេកមានត្រីអណ្ដែងធំត្រីផ្ទក់ថងស្ងោរចូលគ្នាទៅ ទៅ

ឯងទៅសួរផ្ទះគេទិញត្រយ៉ូងចេកនៅផ្ទះពូផលបងផល ពូផ័តហ្នឹង!!! អញ្ចឹងណាស់គ្រាន់តែខ្ញុំ

ដើរ ទៅឯងទិញត្រយ៉ូងចេក 1សួរគេមើលគេលក់អស់ដល់តែពេលខ្ញុំដើរតាំងតាំងខ្ញុំទៅទិញត្រយ៉ូងចេកដល់ហើយភណ្ឌ័ហ្នឹង ម៉ែរបស់នាទៅលក់បង្អែមអត់នៅផ្ទះ ភណ្ឌ័ៗ ត្រយ៉ូងចេកនិងលក់ឲ្យអញអត់ទេហា!! អញយកទៅស្ងោកង្កែប គេចង់ស្ងោរស្ងោកង្កែបជាមួយត្រយ៉ូងចេក !! ហ៊ី មីងមីង វីម្ដាយរបស់ខ្ញុំអត់នៅផង ខ្ញុំចង់សួរតែខ្ញុំអត់មានកាត់សួរផង អត់ហ៊ានសួរដែរនិងណាស់ទាល់តែម៉ែរបស់ខ្ញុំមអត់ហ៊ានសួរដែរនិងណាស់ទាល់តែម៉ែរបស់ខ្ញុំមក ម៉ែមិនដឹងថ្វើរមាណ!! ទម្រាំតែមកម៉ោង 5 ម៉ោង 6 ហើយ !! ហ៊ី អញ្ចឹងឯងកាត់គល់ស្លឹកគ្រៃទៅអញ ឡើងសួរ ដល់ពេលគាត់អញ្ចឹងខ្ញុំក៏យកកូនកាំបិតកាត់គល់ស្លឹកគ្រៃផ្ទះរបស់បងខ្ញុំខ្ញុំដាំបាយឆ្អិនហើយនៅតែសួដល់ពេលហើយគាត់ក៏សួរ គាត់ឡើងសួរអូនអើយរាល់ដងដាំបាយតែមួយកំប៉ុងកន្លះស៊ី3នាក់ 4នាក់ទាំងម្ដាយទាំងកូន ស៊ីមិនអស់ទេដល់តែពេលថ្ងៃនិងបាយ 3 កំប៉ុងស្ងោកង្កែបនិងស៊ីឡើង រលើង ឆ្នាំងដល់ហើយស៊ី មួយទៀតគាត់ទៅបង់សំណាញ់ គាត់ថាឯងដាំបាយឆ្អិនៗស្ងោរ ចៀនកំពតអោយអញ ផងណាស់ កំពតគាត់៣ មានអាមួយសទាំងអស់មានអាមួយក្រោយលាក់ក្រោយវាខ្មៅ វាមាន៣ កុំដាំបាយឆ្អិនអស់ហើយពេលហើយខ្ញុំក៏ចៀនកំពត!!!អញ្ចឹងមកដល់ពេលមកស៊ីបាយៗចឹងនេះគាត់

ស្អូរ ឆ្ងាញ់ណាស់មីអូន!!ស្ងោកង្កែបនិងដល់ហើយគាត់ថា មើលៗឡើងស្ង ៗឡើងស្ង ស៊ីបាយលិតឆ្អាំង បាយអស់សម្ល មែនគាត់និយាយថាបាយអស់ឆ្អាំងអស់បាយអស់សម្ល!!

ក: ជាមួយគាត់អីទាំងអស់និងមែនទេអ្នកមីង?

ខ: ហ្នឹងហើយខ្ញុំនិយាយមែនហើយគាត់នៅកន្លែងនេះគាត់ត្រូវ គាត់កើតបួសហើយដល់ពេលហើយបងបងអញ្ចឹងមានរន្ធតែមួយទេ ដល់ពេលយូរយូរទៅគាត់លុបមុខវាមិនកាន់ វាប៉ះដៃវាមិនក្រិនក្រិនឡើងមួយទៀតមួយទៀតដល់ពេលយូរយូរទៅឡើយលុបមុខអញ្ចឹងទៅរាល់ថ្ងៃចេញមួយទៀតឡើង រន្ធ៣ រន្ធ3 ហៅឡើងហើមបន្តិចហើយថ្ងៃនឹងគាត់ធ្វើការនៅក្រុមហ៊ុននៅភ្នំពេញនិងនៅម៉ុំបឹងកេងកងនិង បងរបស់ខ្ញុំមេជាងដល់ពេលហើយថ្ងៃនឹងគេជួបលាងណាស់ថាថ្ងៃអាទិត្យអញ្ចឹង ជប់លៀងមានលុយមានការៗចឹងទេស៊ីផឹកហើយ គេទិញអីៗមក ឪពុកម៉ាក់គាត់នៅភ្នំពេញគាត់ថាអញ្ចេកប្រាប់បងខ្ញុំថាអញ្ចេក អាអាងឯងទិញប៊ីយ៉ែរទិញអីមក មកផឹកស៊ីអញ្ចឹងចាំខ្ញុំទៅទិញសាច់ក្ដែមមក គេទិញបំពង គេទិញឆាក្តៅមកមាន់យកមកបំពង ដល់ពេលហើយបងរបស់ខ្ញុំទិញស្រា រួចហើយហើយប្តីរបស់ខ្ញុំទៅហើយពួកម៉ាករបស់គាត់នៅភ្នំពេញគាត់មកគាត់ច្រឡំដាក់មួយដៃអញ្ចេក គាត់ថាដឺ លេង

ហើយចុះទីនេះ អ៊ូយអាចោម្រ៉ាយ ចំកន្លែងហើមដៃហើម អញមិនទាន់ស្រុកផង អ៊ូយអ៊ូយ ថាថា អ៊ូយថាកុំខឹងអីខ្ញុំច្រឡំច្រឡំរ៉ៃ ដល់តែពេលថ្ងៃស្អែកឡើងអូនអើយហើមហើមហើម ឡើងខ្មៅឡើងនខ្មៅស្រាប់តែបងខ្ញុំនេះបងបន្ទាប់ខ្ញុំ ហ៊ី ប្តីអាវីហើមអញ្ចឹងក៏មិនទិញថ្នាំលាប អត់ទេខំផឹកស្រាទៀត គាត់ផឹកដែរណាស់!! ក៖ចាំ!! ខ៖នៅក្នុងផឹកស្រាទៀតប្រយ័ត្នទៅ ឈោរតែហើមងាប់ ហ៊ីបង ដល់ពេលថ្ងៃមួយគាត់ហូបនៅក្នុងកាបូបគាត់ គោលដៅកាបូប គាត់នៅក្នុងហោប៉ៅខោ គាត់ចេញពីធ្វើការពេលល្ងាចហូតកាបូបមក ខ្វាក គាត់ដកលុយ ក្រដាស 10000 ក្រដាស 10000 ស្រាប់តែគាត់រកទិញប៊ីយ៉ែរ ក្តួយខ្ញុំចាប់បើកតូប ចាប់ហួយធំសព្វថ្ងៃហ្នឹង!! ក៖ចាំ!! ខ ៖ដល់ហើយខ្ញុំថាអញ្ចេក អើយហូតលុយមកខ្វាច់ ក្រដាស 10000 មកទិញហើយស្រាប់តែបងខ្ញុំអញ្ចេក ចាប់ឆក់ភ្លាម ហ៊ី មុខស្រលាញ់ ហើមពោរឡើងខ្មៅងួញង អត់ព្រមទិញថ្នាំលេបទេអាលែងតែផឹកស្រាជិតងាប់ទៅ រដ្ឋអ ញ្ចេកបងខ្ញុំអត់បារម្ភអីទេព្រោះខ្ញុំចំណាស់ណាស់ហើយខ្ញុំងាប់ងាប់ទៅ កុំឱ្យតែកូនរបស់ខ្ញុំ ងាប់ គាត់ថាអញ្ចឹង កុំអោយតែកូនប្រពន្ធរបស់ខ្ញុំងាប់ខ្ញុំងាប់អីងាប់ទៅ ខ្ញុំចំណាស់នេះទេ ហើយខ្ញុំគ្មាន បារម្ភអ្វីទេ ហើយបងខ្ញុំថាចំណាស់នេះត្រឹមតែក្មេងប៉ុណ្ណឹង!!!

ការសម្ភាសន៍ ប

ន្តរបស់អ្នកមីងឆេងរី

ក: ថ្ងៃនេះខ្ញុំមានសេចក្តីអំណរគុណមែនទែនដែ

លបានសម្ភាសន៍អ្នកមីងម្តងទៀតដោយសារកាលពីមុនការសម្ភាសជាលើកទី 2 គឺមិនទាន់

បានបញ្ចប់ទេដោយសារអ្នកមិនរវល់មែនទេអ្នកមីង? អញ្ចឹងថ្ងៃនេះមកសម្ភាសន៍អ្នកមិនបន្ត

ឲ្យហើយដោយសារពេលមុនបានសួរអំពីការសិក្សាហើយនឹងបានសួរអំពីស្វាមីបានផ្លាស់ខ្លះ

ហើយអញ្ចឹងស្វាមីរបស់អ្នកមីងពេលមុន  អ្នកមីងប្តីពេលមុនគាត់ស្លាប់មែនទេអ្នកមីង ?

ខ: គាត់ស្លាប់គាត់ស្លាប់យូរឆ្នាំដែរហើយវត្តស្លាប់យូរឆ្នាំហើយខ្ញុំចង់ចាប់ជាតិទៅនៅរកសាប៊ូ

ឆ្នាំហើយឥឡូវចាប់ជាតិនៅបានប៉ុនណាណើទៀតហើយ ។

ក: នឹងមែនទេ?

ខ: ប្តីរបស់ខ្ញុំចាប់ជាតិមកទៀតហើយបាន 7 ឆ្នាំហើយ។

ក: ហ្ន៎ អ្នកមីងជឿលើការចាប់ជាតិមែនទេ?

ខ: ហ្នឹងហើយនៅឯណោះនៅកំពតឯនោះនភស្រុកកំពតឯណោះស្រុករបស់គេនៅកំពត។

ក ៖ហ្ន៎!! ខ៖ឥឡូវចាប់ជាតិនៅស្រុកកំពតចាប់ជាតិនឹងនៅជាមួយប្អូនទៀត នៅជាមួយប្អូន អ្ហូនមានប្តីចាប់ជាតិនៅជាមួយមីប្អូនទេប្អូននឹងមប្អូនងាប់បាត់ហើយ នៅកូនកូដល់ពេលមាន ប្តីមានប្តីមានកូនម៉ែដឹងម៉ែវាហ្នឹងងាប់កូនធំក្រមុំទៅហើយចាប់ជាតិមកនៅជាមួយនឹងកូនគេ នៅជាមួយនឹងកូនហ្នឹង ហើយបើម៉េចម៉េចបើបានមកត្រូវនៅជាមួយនឹងកូន ចាឥឡូវនៅជាមួយកូនទេតែឥឡូវប៉ុនណាណើហើយនោះ
ឥឡូវធំហើយនៅទីហ្នឹងឥឡូវដល់ពេលខ្ញុំទៅលេងឥវ៉ាន់!!ហើយខ្ញុំហៅខ្ញុំម្តងហើយម្តងហៅ នេះម្តងហើយប្រពន្ធ។

ក: ហ្ន៎ នៅចាំដែរមែនទេ?

ខ: ចាបានសំដីណាស់!!!ហើយបានកូនខ្ញុំនៅជាមួយដែលកូនខ្ញុំនៅទីណានៅជិតគ្នាកូនខ្ញុំ ហើយនិយាយឥវ៉ាន់និយាយអញៗ ហើយថាអញ្ចេក អញជាប៉ាហៅ និយាយជាមួយអញៗ ថាអញ្ចឹងហេ ចុះបើខ្លួនឯងប៉ុនថៃឲ្យគេហៅនិយាយខ្ញុំនិយាយឆ្លើយចាថាយ៉ាងម៉េច!!!យី អញប៉ាណាស់ ថាអញ្ចឹងហិ!!

ក: យីសុទ្ធតែអញ្ចឹងតែម្តង។

ខ: គាត់អត់បានទេឆ្នាស់ហើយតាទៀតណាស់ហើយដល់ពេលខ្ញុំនៅក្នុងទៅលេង ខ្ញុំមកវិញ ហើយនិយាយថាទៅលេងដែរឬអត់?ឈ្មោះរិទ្ធកាលពីពេលមុនគាត់ឈ្មោះថា!!ល្អតែចាប់ ជាតិឥឡូវឈ្មោះរិទ្ធ!!!

ក: ប្រុសដដែរមែនទេអ្នកមីង?

ខ: ចិត្តដល់ពេលឥឡូវឈ្មោះថា។

ក: ឈ្មោះថា ។មើលនាក់នេះឥឡូវនិយាយប្រាប់ពីពេលស្នេហាដំបូងហើយយ៉ាងម៉េចបានជួបគាត់?ខ្ញុំភ្លេចហើយខ្ញុំបានសួរអ្នកមីងហើយរស់នៅតែអ្នកមិននិយាយប្រាប់ខ្ញុំម្តងទៀតមក!!!មុនដំបូងយ៉ាងម៉េចបានជួបគ្នាជាមួយនឹងស្វាមី?

ខ: បើមុនដំបូងខ្ញុំមិនដែលស្គាល់គេដែរតែស្គាល់តាមរយៈខ្សែរយៈរបស់ខ្ញុំនៅពោចិនតុងចានៅពោចិនតុងគាត់ គាត់ធ្វើទាហ៊ានទាហានសក្តិមួយណាស់!! ក៖ចាំ!!ខ៖គាត់ធ្វើខ្លាំងណាស់ទាហានស័ក 1 មានកាំភ្លើងខ្លីមានអីហើយគាត់នៅពោធិចិនតុងខ្ញុំមិនដែលខ្ញុំមិនដែលស្គាល់ខ្ញុំនៅធំជាងនេះបន្តិចហិ!!!ខ្ញុំទៅតាមបងថ្លៃខ្ញុំបងថ្លៃរបស់ខ្ញុំទៅលក់ពងទាកូននៅផ្សារពោចិនតុង ហើយដល់ពេលម៉ោង ៣ ម៉ោង 4គាត់ចាប់ផ្តើមទៅហើយហើយដល់ខ្ញុំ ហើយដល់ពេលល្ងាចម៉ោង 5 បានជាខ្ញុំធ្វើខ្លួនសិតសក់អ្វីដើរតាមពីក្រោយពីក្រោយគាត់ទេខ្ញុំរៀបចំទុកដាក់អីហើយដើរតាមក្រោយគាត់គាត់មកពីគាត់ចេញទៅហើយទៅលក់ហើយ។

ក: ហ្ន៎ មីងបានប្រាប់ថាមានគេញ៉ែអ្នកមីងពួកសិស្សសាលាអីនឹងមែនទេ?

ខ: ចាំ ចាំ ហើយដល់ពេលគាត់ស្គាល់គ្នាគាត់មកបងថ្លៃរបស់ខ្ញុំស្គាល់ខ្ញុំទេគាត់បងថ្លៃខ្ញុំយប់ឡើងល្ងាចប្រហែលជាម៉ោង 5 ម៉ោងគាត់មកហើយប៉ូលីសកាំភ្លើងខ្លីមានគ្រាប់បែកមានដាក់ពីមុខគាត់ហើយកាំភ្លើងខ្លី។

ក: គ្រាប់បែកទៀត?

ខ: មានគ្រាប់បែកចុះគាត់ជាអ្នកការពារហៅគាត់ការពារគាត់ហើយគាត់ចូលហូបពងទាកូនបងថ្លៃខ្ញុំអញ្ចឹងណាស់ដងហើយខ្ញុំនៅប៉ុនេះស្អាតណាស់សក់ខ្ញុំត្រឹមណាស់ហើយខ្ញុំឆ្មាស់ណាស់ប្រុសណាមកខ្ញុំអត់បានទេខ្ញុំប្រាប់គ្រាន់តែមើលមុខខ្ញុំមិនបានទេហើយគាត់ថាបងថ្លៃរបស់ខ្ញុំសួរថាអញ្ចេក ហ៊ី នឹងត្រូវយ៉ាងម៉េច? ហ៊ីប្អូនថ្លៃរបស់ខ្ញុំតាអញ្ចឹងហិ ហើយអញ្ចឹងគ្រាន់តែមើលមុខអត់បានទេមុខស្លុតតែសម្លក់ខ្ញុំអញ្ចឹង!! ហ៊ី មើលមុខមិនបានទេមើលមុខវាមិនបានទេដល់ហើយហើយខ្ញុំខេត្តខ្ញុំពីមុនហៅខ្ញុំមករាល់ថ្ងៃ ពេលឃើញខ្ញុំមករាល់ថ្ងៃ អញ្ចាក!!ម្តងហើយខ្ញុំអាម៉ុម្តងហើយខ្ញុំមានអូន អស់ពីមីអូនអាម៉ុ ហើយហៅខ្ញុំហូបពងទាកូនហី? ខ្ញុំអត់ឆ្លើយទេ!! ហូបពងទាកូនរឿងអី??ខ្ញុំអត់ឆ្លើយទេស្រាប់ហើយដល់ហើយហៅខ្ញុំ

ទៀតហើយខ្ញុំថាពិសាខ្លួនឯងឲ្យឆ្អែតទៅ មានប៉ុន្មានប៉ាវគេ?ខ្ញុំថាអញចឹងណាស់ហើយខ្ញុំ

ដែររុយខ្ញុំដើរចេញហើយ ហើយដល់ពេលហើយបាត់យូរណាស់ហើយស្អែកឡើងមកទៀត

អ៊ើឡើងមុខទៀតហើយខ្ញុំទៀតខ្ញុំថាអញ្ចេក បងអាប៊ិនេះស៊ាំញ៉ែដល់ហើយ និយាយច្រើនដង

ពិបាកខ្ញុំបាញ់ចោលឥឡូវហើយខ្ញុំឥឡូវហើយខ្ញុំថាអញ្ចឹងណាស់!! ហ៊ីកំមាត់ទាក់ម៉ូយ ព្រោះ

មួយនិងអង្គការម្នាក់នឹងធ្វើការធំណាស់មកស៊ីពងទាកូនម្តងៗធំៗណាស់ម្តងៗ 10គ្រាប់អ៊ី

នោះ!!! ស៊ីអត់អស់អត់យកទៅទៀត គិតលុយគិតកាក់ឲ្យហើយអញ្ចឹងកុំមាត់កុំមាត់ប៉ាៗ

ទាំងនេះដល់ហើយគាត់មើលមុខខ្ញុំ ដងហើយខ្ញុំថាស៊ីស៊ីទៅប្រយ័ត្នខុសចាន!!! អាល័យ

សម្លឹងមើលគេនឹងខ្ញុំថាអញចឹងណាស់ ដល់ពេលស៊ីយូយូទៅសួរបងថ្លៃខ្ញុំថាចង់ស្រលាញ់

អូនថ្លៃថែឯងដល់ហើយ!! បងខ្ញុំថាអញ្ចេក ហ៊ី

ចង់ស្រលាញ់ដល់ពេលហើយយូយូតាមពុកខ្ញុំ

តាមម៉ែខ្ញុំតាមបងរបស់ខ្ញុំទៅផ្ទះហើយដល់ហើយគាត់មានម្តាយរបស់គាត់នៅឯណោះគាត់

ហើយគាត់មកផ្ទះខ្ញុំលេងរាល់ថ្ងៃលេងមករាល់ថ្ងៃយប់ឡើងគាត់មកហើយយប់ឡើងគាត់មក

ហើយជិះកង់មកហើយមិនអញ្ចឹងជិះម៉ូតូមកហើយថាជំរាបសួរម្តាយរបស់ខ្ញុំជម្រាបសួរម៉ែខ្ញុំ

ជម្រាបសួរឪពុកខ្ញុំឪពុកចុងរបស់ខ្ញុំនឹងណាស់!! កៈចាំ!!ខៈជំរាបសួរហើយម៉ែរបស់ខ្ញុំសួរ

ថាអញ្ចេក ហ៊ីផ្ទះអាអូនឯងនៅឯណា?

ហ៊ី ខ្ញុំនៅកំពតស្រុករបស់ខ្ញុំនៅកំពតប៉ុន្តែខ្ញុំធ្វើការនៅតំបន់ទី 3 នេះខ្ញុំអត់សូវដែលទៅម្តាយខ្ញុំទេយូយូ2 ឆ្នាំម្តងបីឆ្នាំម្តងបានទៅហើយឥឡូវខ្ញុំសុំ!! បានហើយស្អែកឡើងទៀតមកដល់ទៀតពេលថ្ងៃស្រាប់តែមកអង្វរម្តាយរបស់ខ្ញុំថាអញ្ចេក អ៊ំៗ ខ្ញុំអត់មានម៉ែម៉ែរបស់ខ្ញុំនៅឆ្ងាយខ្ញុំមានរបស់របរមកខ្ញុំពិបាកទុកដាក់ទុកដាក់ណាស់ឥឡូវខ្ញុំសុំធ្វើកូនធម៌អ៊ំឯង ហើយណាស់តាអញ្ចឹងនេះ!!! សុំធ្វើកូនធម៌អ៊ំ ឯងពេលខ្ញុំបើកលុយបើកអីបើកលុយបើកប្រាក់ខ្ញុំយកមកឲ្យអ៊ំឯង របបរបស់គាត់បឹកន្លែងណាស់របបរបស់កូនរបបប្រាក់ខែគាត់របបស្អីៗច្រើនណាស់2 3 មុខណាស់របស់គាត់ ហើយគាត់បើកលុយម៉ោងហើយរបស់អង្ករផ្សេងហើយដល់ពេលហើយគាត់ថា  អញ្ចឹងបើសុំធ្វើធ្វើទៅខ្ញុំហៅម៉ែឯងថាម៉ែណាស់!!!អញ្ចឹងម៉ែឯងក៏ហៅខ្ញុំថាកូនខុសហើយចុះ!!!ហៅអីហៅទៅ!!ហេកូនឯងធ្វើកូនធម៌ទៅហើយហៅម៉ែកោះហៅកូនឯងកូន ហើយអញ្ចឹងបានធ្វើកូនធម៌របស់ម៉ែរហូត រហូត រហូត បានដល់ពេលយូរយូរទៅ ខ្ញុំធំទៅទៅដឹងក** ៊ីថាសុំស្រលាញ់ខ្ញុំ!!! ហើយសូមស្រឡាញ់ខ្ញុំខ្ញុំអត់ដឹងទៀតបង!!!ខ្ញុំអត់ដឹងទៀតអត់ដឹងទេខ្ញុំកំពុងតែកិនម្សៅកិនម្សៅៗចឹងកិនម្សៅរាល់ថ្ងៃសំរាប់លក់

នៅខាងមុខសាលារៀនមួយរយខ្នងណាស់ដល់ហើយខ្ញុំលក់នំលក់អី លក់នំច្រើនមុខ

ណាស់ហួសហេតុទុករបស់ខ្ញុំប៉ុណ្ណឹងនេះផែង!!!ដល់នោះដល់ត្រែ ឯណោះ!!! ក៖ចាំ!!!ខ៖ ហើយមានតែខ្ញុំទេលក់ដាច់នោះមានសិស្សសាលាចូលមានតែធំធំទេហើយសិស្សសាលាចូល ឯកទឹកក្បាលណាស់ក្នុងមួយថ្ងៃដាំចិត្ត 10 កំសៀវ!!! គ្រាន់តែដាំទឹកឆ្អែកណាស់ សុទ្ធតែអនាម័យណាស់ ថ្ងៃ 1 ថ្ងៃផឹកទឹកក្តៅ វាអោយលុយ អាវាចូលទិញនំស៊ី អោយលុយហើយដោយទិញនំស៊ី ផឹកទឹកក្តៅវាអោយលុយ គ្មានផ្ទះណាអនាម័យទេមានតែផ្ទះគាត់ទេផឹកតែទឹកក្តៅ ចូលផ្ទះរបស់គាត់ផឹកទឹកក្តៅ។

ការសំភាសន៍តរប

ស់អ្នកមមីងឆេង រី

ក៖ អញ្ចឹងសូមបន្តទៀតដោយសារអ

ម្បាញ់មិញមានការរំខាន។

ខ៖ ដល់ពេលហើយម៉ែញុំមថា ដល់ពេលហើយម៉ែញុំមថាម៉េចនាំញុំមទៅគាត់អោយម៉ែញុំមដាំបាយពេលកាលហ្នឹងអត់ទាន់មានឡានទេ

ស្រុកហ្នឹងពេលហ្នឹងជិះរទេះភ្លើង។

ក៖ មានរទេះភ្លើងទៀត!!!

ខ៖ កាលហ្នឹងមានរទេះភ្លើងមានរទេះភ្លើងគាត់ទៅកំពតជិះរទេះភ្លើង ដល់ពេលឥលូវគេជិះឡាន ម៉ែដាំបាយអោយញ៉ុមព្រោះញ៉ុមចង់ទៅផ្ទះម៉ែញ៉ុម ងើបពីយប់ទៅផ្ទះម៉ែខ្ញុំជិះរទេះភ្លើងអញ្ចឹងហើយបានបាត់គាត់ ដល់បាត់គាត់ហើយ ម៉ែដូចបាត់អាតាប៉ុហ្នឹងទៅណា? ញ៉ុមដូចខឹង ដូចបាត់អាតាប៉ុមួយហ្នឹង ពេលមុនមករាល់ថ្ងៃហេតុអីថ្ងៃនេះអត់ឃើញ?

ក៖ ហ៊ីនឹកគេម៉ង?

ខ៖ ដល់ពេលអញ្ចឹងទៅម៉ែញ៉ុមថាអញ្ចេក កូនកូន ឥឡូវម៉ែនិយាយប្រាប់កូនឯងតាមត្រង់!! ម៉ែញ៉ុមនិយាយថាអញ្ចឹងណាស់ !!គេទៅផ្ទះម៉ែគេគេហៅម៉ែគេអោយមកមើលកូនឯងនិយាយអញ្ចឹងហា៎!! ចុះហៅមកមើលខ្ញុំ ខ្ញុំមានឈឺអី!!ហើយញ៉ុមថាចុះម៉ែហៅគេមកមើលញ៉ុមញ៉ុមមានឈឺអី ញ៉ុមទៅលក់ដូររាល់ថ្ងៃហៅមកមើលញ៉ុមម៉េច?និយាយអ៊ីចឹងហិ!! ហ៊ីអត់អីអត់អីទេកូន គេទៅម៉ែគេមកកូនឯងជំរាបសួរណាស់ ញ៉ុមថាដល់ហើយញ៉ុមថា បង

ញ៉ុមបងញ៉ុមមានមួយទៀតញ៉ុមថាអញ្ចេកនោះនៅផ្ទះនោះ បងញ៉ុមនៅក្រមុំហា៎!!ក៖ចា៎!! ខ៖ នៅក្រមុំ នៅក្រមុំអត់ទាន់មានប្ដីទេ ដល់ហើយអោយញ៉ុមជំរាបសួរចុះអារ៉ុអោយជំរាបសួរអត់អញ្ចឹងចុះ?ញ៉ុមថាអញ្ចឹងហិ!!ញ៉ុមជំរាបសួរម្នាក់ឯងអញ្ចឹងអារ៉ុអត់អោយជំរាបសួរទេអញ្ចឹង!! គាត់ថាហ៊ីអោយជំរាបសួរទាំងពីរនាក់ហ្នឹង អញ្ចឹងហិ ដល់ពេលហើយញ៉ូមលក់ឥវ៉ាន់ ញ៉ុមលក់អីវ៉ាន់ហើយញ៉ុមមកប្រហែលរថភ្លើងមកដល់វ៉ាវាម៉ោងជិត៨ ៩ហើយ ហើយទំរាំតែមកដល់ផ្ទះហ្នឹងម៉ោងជិត១០ហើយ អញ្ចឹងហិ!!ចុះពីពោធិចិនតុងមកដល់សាលារៀន១០០ខ្នង វាឆ្ងាយដែរទំរាំតែមកដល់ដើរ មានអីជិះកាលហ្នឹងមានម៉ូតូឌុបមានអីមកពីណា!! មានតែកង់ឌុប កាលហ្នឹងអត់មានស៊្ទីមានតែកង់ឌុបហ្នឹងហើយដល់ហើយគាត់ដើរ ដើរមកដល់ណោះ លែងម៉ោងជិះ១០ ស្រាប់ហើយម៉ែដាស់ខ្ញុំ កូនៗមកហើយ !! អ្នកណាគេមក? ញ៉ុមឡូឡាអញ្ចឹង អាណាមក អាណាមក?អាណាមកមកទៅ ញ៉ុមនិយាយអញ្ចឹងហិ ញ៉ុមថាអញ្ចឹងហិ អាណាមកមកទៅ

តែមកហ្នឹងឪពុកក្មេកខ្ញុំហ្នឹងមកមុនប៉ុន្តែម៉ែក្មេកញ៉ុមហ្នឹងអត់

មកទេ បងអើយមក យកមាន់យកទាយកលុយទុកចងដៃញ៉ុមហា៎ ហើយនំណែកហើយទាមាន់ ហើយដល់ពេលហើយញ៉ុមខឹងមែនទែន !!ទៅទៅជំរាបសួរ ឪពុកក្មេកង៉ែងមកហើយជំរាបសួរ !! ទេខ្ញុំមានឪពុកក្មេក ឪពុកក្មេកញ៉ុមឯណាទេ ញ៉ុមមានឪពុកក្មេកឯណាអោយ

ជំរាបសួរ ញ៉ុមថាអញ្ជឹងហិ ញ៉ុមរាល់ថ្ងៃញ៉ុមនៅម្នាក់ឯងម្នាក់ឯងញ៉ុមមានឪពុកក្មេកឯណា មានតែម៉ែយាយញ៉ុមហ្នឹងញ៉ុមមានឪពុកក្មេកមកពីណា!!!ថាអញ្ជឹងហិ!!

ក៖ មីងមានអាយុប៉ុន្មានពេលហ្នឹង?

ខ៖ ម៉ែញ៉ុម! ចាំ?

ក៖ មីងមានអាយុប៉ុន្មានពេលហ្នឹងហាំ?

ខ៖ ញ៉ុមទឹមតែប៉ុន្មាន១០ហ្នឹង!!ក៖ហ្ហ៎!!ខ៖ ចាំដល់ហើយទឹមតែប៉ុន្មាន១០ ដល់ហើយញ៉ុមនៅចេះធ្វើខ្លួន ញ៉ុមធ្វើខ្លួនសក់ញ៉ុមត្រឹមចង្កេះហ្ហ៎!! ដល់ពេលហើយហៅញ៉ុម ដល់ពេលហើយលេងមួលញ៉ុមហិ ដល់ពេលមួលញ៉ុមញ៉ុមស្រែកតែម្តង !! ដឹងស៊្មីម៉ែ ខឹងគេអត់មកជំរាបសួរមួលគេតែម្តងនេះ!!ក៖ចាំ!!ខ៖ញ៉ុមថាអញ្ជឹងហិ អូយញ៉ុមអាក្រក់ណាស់ ញ៉ុមថាអត់ស្តាប់ឯង ហេម៉ែឯងខូច អោយគេមកជំរាបសួរ ញ៉ុមអត់មកជំរាបសួរមកមួលខ្ញុំ ហើយមិនអោយអារ៉ុមកជំរាបសួរ?គាត់អោយបងជំរាបសួរហើយញ៉ុមចេញមក អារ៉ុបងញ៉ុមជំរាប

ហើយញ៉ុមជំរាបសួរដែរ ហើយចេញពីក្រៅក្នុងផ្ទះមក ទៅតាមសំយ៉ាបផ្ទះក្រៅ !! លែងព្រលឹមឡើងបងអើយ លែងគាត់ខឹង ទិញប៊ីយ៉ែយទិញផឹកខ្ទេច។

ក៖ មិនអើទៅទិញស្រាផឹកហេ?

ខ៖ ហ្នឹងហើយ គាត់អត់ចេះផឹកស្រាផងហ្នឹង គាត់អត់ចេះផឹកផង ដល់ហើយគាត់ហៅគេហៅឯងផឹកហៅគេជិតៗហ្នឹង លែងទិញប៊ីយ៉ែយពីកេស លែងអាមាន់ទាធ្វើអោយ ធ្វើឡើងអ្នកនៅជិតហ្នឹងគេធ្វើ គេធ្វើបំពងធ្វើអី ធ្វើបំពង ឆាក្ដៅឆាអីអញ្ចឹង ហើយដល់ហើយម៉ែញ៉ុមថាអញ្ចេក ណោះមើលឪពុកក្មេកឯងថា ប្រាប់ម៉ែញ៉ុមថាមកដល់គាត់ថាបើកូនប្រសារហ្នឹងជំរាបសួរគាត់ចងដៃ គាត់ចងដៃហា៎ យកលុយហ្នឹងចងដៃចងដៃហើយប្រគល់ទាប្រគល់មាន់ ហើយដល់ហើយអត់ជំរាបសួរព្រលឹមឡើងគាត់ខឹងញ៉ុមប៊ីយ៉ែយពីកេសមកហើយអាមាន់ហ្នឹងធ្វើខ្វៃធ្វើអី

ធ្វើបំពងធ្វើអីឆាក្ដៅអីនាំគេហៅគេហៅឯងស៊ីផឹកទៅ!ស៊ីផឹកខ្ទេចព្រលឹមឡើងទៅរ៉ុយបាត់អត់មានមាត់ករអីមួយម៉ាត់ ម៉ែញ៉ុមខឹងម៉េចគាត់ខឹងហើយ!! ហេខឹងខឹងទៅញ៉ុមមានម៉ែក្មេកឪក្មេកណាអោយញ៉ុមជំរាបសួរ ញ៉ុមថាអញ្ចឹងហិ!!

ក៖ ហើយបានប៉ុន្មានខែក្រោយមកបានអ្នកមីងយល់ព្រមរៀបការជាមួយគាត់?

ខ៖ ហើយដល់ពេលហើយយូរយូរទៅ ញ៉ុមថាញ៉ុមថានៅមុខកូនគាត់ហ្នឹង ដែលគាត់ហៅថាកូនកូនថាដែលស្រលាញ់ញ៉ុមហ្នឹងហាំ!!ក៖ចាំ!!ខ៖ប្ដីញ៉ុមហ្នឹងដែលថាមុខកូនគាត់ហ្នឹងដល់ហើយអត់មាត់ទេ ដល់ពេលហើយសារក្រោយគាត់ទៅទៀតទៅទៀតគាត់ហៅម៉ែគាត់មក ម៉ែគាត់មកបានគាត់រៀបចំ បានញ៉ុមជំរាបសួរបានគាត់ធ្វើក្រវិលធ្វើអីអោយខ្ញុំ បានគាត់ធ្វើក្រវិលអោយខ្ញុំបានធ្វើក្រវិលធ្វើអីដល់ពេលបានអញ្ចឹងបាន ដល់ពេលមកការមកការនៅនេះដល់ពេលហើយមកភ្ជាប់ពាក្យភ្ជាប់អីនៅស្រុកដំណាក់សង្កែហ្នឹងណាស់!!ក៖ចាំ!!ខ៖មកភ្ជាប់ពាក្យនៅភូមិដំណាក់សង្កែ ហើយដល់ពេលហើយគាត់មកជិះរម៉ក់ហើយពេលបងមកគាត់ធ្លាប់ជិះរទេះសេះ គាត់ធ្លាប់ជិះតែរម៉ក់គាត់គោងខ្ញុំអើយគោងគាត់ខ្លាចធ្លាក់ងាប់ គាត់អង្គុយកណ្ដាលគាត់គោងជាប់ម៉ែក្មេកញ៉ុមគាត់ខ្លាច។

ក៖ ហ្នឹងហើយ!!

ខ៖ ដល់ហើយមកការនៅនេះ ដល់ហើយការហ្នឹងស៊ីការហ្នឹង ដល់ហើយនិយាយត្រូវគ្នាថាហ្នឹង ថាចេញលុយញ៉ុមចេញលុយដែរ ដល់ពេលហើយគាត់ថាស្រុកហ្នឹងមកការញ៉ុមអត់ហ៊ានមកការទេ មកការកូនញ៉ុមអត់ហ៊ានមកការ ការកូនញ៉ុមអត់ហ៊ានមកការទេ ញ៉ុមខ្លាចហា៎!!ផិះរម៉ក់ខ្លាចណាស់ ហើយទៅលើគាត់ទាំងអស់ ហើយនៅលើគាត់ទាំងអស់ទៅ ណាផិះរទេះភ្លើងទៅលុយលើគាត់ទាំងអស់!!ចា៎លើគាត់ទាំងអស់!!

ក៖ ហ្អ៎អញ្ចឹងក៏រៀបការនៅកំពតទៅ?

ខ៖ ចា៎!!ហ្នឹងហើយ ទាំងអីទាំងអីគាត់កាត់២កំផ្លេ អីៗអីៗនៅលើគាត់ទាំងអស់ លើគាត់ទាំងអស់ទៅខាងប្រុសទាំងអស់ទៅ គាត់មកម្តងគាត់ខ្លាច គាត់មកភ្ជាប់ពាក្យម្តងគាត់ខ្លាច ហើយដល់ពេលថ្ងៃការគាត់លែងហ៊ានលែងមក គាត់ថានៅលើគាត់ទាំងអស់អោយទៅការនៅខាងណោះវិញហ្នឹង!!ក៖ចា៎!!ខ៖ លើគាត់ទាំងអស់ទៅ។

ក៖ចា៎អញ្ចឹងអ្នកមីងពេលរៀបការហើយអ្នកមីងមានកូនប៉ុន្មាននាក់ដែរ?

ខ៖ ញ៉ុមការហើយ ការហើយបានកន្លះខែប្ដីញ៉ុមចេញទៅឆ្នាពង ហើយញ៉ុមចាប់ផ្ដើមមានប្រុសដែរ!!

ក៖ អញ្ចឹងអ្នកមីងកូនប៉ុន្មាននាក់ទាំងអស់?ខ៖ ចាំ?ក៖ កូនទាំងអស់ មានកូនប៉ុន្មាននាក់?

ខ៖ ៥នាក់ នេះពៅគេ មីមួយនេះពៅគេ។

ក៖ ហើយមិញមីងនិយាយស្ដីគេថាប្ដីទៅមីងមានអីគេដែរ?

ខ៖ស្ដាប់ញ៉ុមនិយាយសិន ដល់ពេលហើយញ៉ុមការបានប្រហែលបានមួយអាទិត្យចុះហើយប្ដីញ៉ុមគាត់ទៅឆ្នាពង ឆ្នាពងញ៉ុមចាប់ផ្ដើម មកប្រាប់ប្ដីម៉ែញ៉ុម ប្ដីញ៉ុមហ្នឹងហាំថាម៉ែឯងម៉ែឯងមើលគេផងណាស់ មើលអាមុំផងណាស់ ហៅញ៉ុមតែអាមុំអាមុំទេ!!ម៉ែមើលអាមុំផងព្រោះញ៉ុមទៅណោះ!! ហើយដល់ពេលហើយញ៉ុមនៅសាលារៀន១០០ខ្នងនេះ ហើយគាត់ដាក់អញ្ចឹងកាំភ្លើង កាំភ្លើងនៅនឹងចង្កេះ ហើយដល់ហើយញ៉ុមអត់អោយបងឯងទៅទេដល់ហើយថាអញ្ចេក ថាឯងទៅធ្វើអីបើឯងមេគេអញ្ចឹងគ្រាន់តែចាត់ចែងអោយកូនទាហាន

អីទៅទៅហើយឯងត្រលប់មកវិញមក គាត់ថាអញ្ចឹងអត់កើតទេទាល់តែទៅកន្លែងហ្នឹងចាត់ចែង អញ្ចឹងចាំមើលញ៉ុមមកវិញក៏បានដែរ ថាអញ្ចឹង ថាទៅតែមួយអាទិត្យទេ ថាទៅពេលហ្នឹង កាលហ្នឹងឡើងអ៊ី កាលមួយហឹកហ្នឹងថាឡើងអ៊ី គាត់ថាទៅរៀបអោយកូនទាហានសិន ថាទៅបើទៅមួយអាទិត្យ បើទៅមួយអាទិត្យយូរណាស់អញ្ចឹងហិ!!កះថា៎!!ខះអញ្ចឹងមួយអាទិត្យយូរណាស់ ទៅមួយអាទិត្យ អញ្ចឹងញ៉ុមអត់ព្រមអោយទៅញ៉ុមយំ ញ៉ុមទៅយំនៅខាងក្រោយផ្ទះហ្ហ៎!!ញ៉ុមយំយំ ហើយអង្វរប្រាប់ញ៉ុមថាអញ្ចេក ហ៊ុឯងកុំយំអីបងទៅតែមួយអាទិត្យទេមកវិញហើយ ព្រោះអីឯងមេគេ មេអត់ទៅអញ្ចឹងម៉េចដឹងកូនទាហានដាក់កន្លែងណាកន្លែងណា ទីណាទីណី ហើយដល់ហើយបានគាត់ហើយញ៉ុមយំយំ ហើយគាត់អង្វរអង្វរញ៉ុមមកផ្ទះបានមកផ្ទះ មកផ្ទះដល់ពេលអញ្ចឹងម៉ែម៉ែ អត់ទាន់បានទៅទេ ចាំមើលស្អែក ឥឡូវញ៉ុមនាំគេដើរលេងហ្នឹងទៅមើលកុន កុននៅសាលាភស្តុភានេះគេលែងកុន ជំនាន់ហ្នឹងគេលែងកុន ហើយម៉ែញ៉ុមអ៊ីថាអញ្ចេក អត់អោយដើរទេ !! គាត់សុំ សុំម៉ែញ៉ុម ម៉ែម៉ែព្រោះអីចាប់ផ្តើមថាគូរដណ្តឹងណាស់ គ្រាន់តែថាគូរដណ្តឹងជិតការហើយនាំគ្នាដើរលេង នាំគ្នាដើរលេងអោយសប្បាយបន្តិច ថាអញ្ចឹង ស្រាប់ដល់ពេលហើយម៉ែញ៉ុមថាហ៊ី!!សុំម៉ែញ៉ុមឯណា ហ៊ីម៉ែម៉ែញ៉ុមសុំអាមុំដើរលេង ដើរលេងឯណា?ដើរលេងនៅសាលាភស្តុភានៅផ្សារពោធិ៍ចិនតុងហ្នឹងទៅមើលកុន។ អត់អោយដើរទេកូន ចាំថ្ងៃការហើយ ការ

ហើយប្ដីប្រពន្ធចាំកូនឯងដើរលេងណាដើរទៅ ខ្មាស់គេកូនណាស់ ព្រោះអីយើងមិនមែន នៅស្រុកយើង មិនមែនស្រុកដំណាក់សង្កែទេ នៅស្រុកគេហ៎ាកុំអោយគេមើលមកថាហ៊ីមក នៅស្រុកគេមានគូរដណ្ដឹងអញ្ចឹងមិនទាន់បានអីផងនាំគ្នាបណ្ដើរបណ្ដើរដើរពេញណាពេញ ណឹអញ្ចឹងហិ!!! ហ៊ើយម៉ែអើយមានអ្នកណាហ៊ានថាទេ យើងដើរយប់គ្មានអ្នកណាគេចាប់ អារម្មណ៍ មកចាប់អារម្មណ៍យើងទេស្រាប់តែម៉ែ ដល់ហើយគាត់និយាយមួយម៉ាត់ពីរមួយ ម៉ាតពីរគាត់គេចញ៉ុម គាត់ទៅទៅ!! ទៅលែងមកវិញអ៊ី អ៊ីញ៉ុម អ៊ីញ៉ុមហ៎ា!!

ក៖ ហ៊ឺម៉ែអ៊ី។

ខ៖ ម៉ែញ៉ុមអ៊ីញ៉ុម គាត់អ៊ីញ៉ុមពីរដៃណាស់។គាត់អ៊ីដៃពេញដៃថាញ៉ុមស្រែកយំថាអញ្ចេក ម៉ែឯងការទៅការជាមួយគេទៅញ៉ុមមិនការទេ សុំដើរមិនបាន ញ៉ុមមានដែលដើរទៅណា គាត់ខឹងញ៉ុមខ្លាំងណាស់ ញ៉ុមប៉ុនច្រៀងណាស់ ពេលចូលឆ្នាំលេងឈូងនៅមុខផ្ទះនៅ កន្លែងផ្ទះហ្នឹង នៅជិតសាលារៀនហ្នឹងហ៎ា!!ក៖ចា៎!!ខ៖ គេថាញ៉ុមចេះច្រៀង ពួកហ្នឹងក្រ មុំៗ ប្រុសៗលេងឈូង  ស្រាប់តែខ្ញុំថាចែចែមកឈរមើលគេ ហើយចុះពួកហ្នឹងអត់ចេះ ច្រៀងទេហេ លេងឈូងជួសធ្វើអីលេងឈូងច្រៀងទៅ!!!លេងឈូងរាំទៅ!!អត់មានអ្នក

ណាគេច្រៀង ដល់ពេលហើយខ្ញុំច្រៀងគេកាន់កាំភ្លើងមក គាត់ថាសំលេងៗបងញ៉ុមច្រៀង ម៉ែម៉ែញ៉ុមទៅនោះមួយភ្លេត ទៅណា?ទៅមើលកន្លែងគេលេងឈ្លួងហ្ន៎ ឈ្លួងនៅកន្លែង ឈ្លួងមានអ្នកណាគេច្រៀងបែបអាម៉ុំហើយហើយទៅមើល ហើយបងថ្លៃញ៉ុមនេះគាត់ថា ណោះអារី អាថាខឹងហ្ន៎ ថាអារីឯងមានខ្លួនហើយខំពូកែដើរ!!ស្អីញ៉ុមមានខ្លួនញ៉ុមមានប្រុស ជាមួយអាណាញ៉ុមថាអញ្ចឹងហិ បងថ្លៃញ៉ុមគាត់ថាញ៉ុមមានខ្លួនកុំប៉ុនដើរ ហើយញ៉ុមនេះ ញ៉ុមអត់ដឹង ក្មេងមានដឹងខ្យល់អី គាត់លាក់ញ៉ុមណាស់ ហើយបងញ៉ុមដឹងម៉ែញ៉ុមដឹង ហើយថាញ៉ុមថាអញ្ចេកអាណាគេចង់បានញ៉ុមហើយ ហើយឥឡូវញ៉ុមសួរអាណាគេចង់ បានខ្ញុំ ហើយញ៉ុមដើរលេងបន្តិចអត់បាន ហើយខ្ញុំម្ចាស់ខ្លួនញ៉ុមអត់មានដឹងខ្យល់គ្របល់ យកតិចសោះនេះហិ ហើយអោយតែខ្ញុំដើរបន្តិចសុទ្ធតែខ្ញុំដើរហើយអត់មានអោយនៅផ្ទះទេ មានខ្លួនអត់នៅផ្ទះទេគិតតែពីដើរ អាណាចង់បានញ៉ុមស្រាប់តែញ៉ុមថាអញ្ចឹងហិ!! ស្រាប់ ហើយថាកុំមាត់មាត់ គង់តែដឹងទេ បងញ៉ុមថាអញ្ចឹងណាស់ គង់តែដឹងទេ បងថ្លៃញ៉ុមនេះ នៅ នៅដំណាក់សង្កែហិ មើលគង់តែដឹងទេ គង់ដឹងមើលនិយាយប្រាប់មើលគេណាចង់ បានញ៉ុមញ៉ុមអត់ដឹងសោះហើយចុះអាណាចូលអត់អោយមានគេដឹងខ្លួនសោះអញ្ចឹង ញ៉ុម ថាអញ្ចឹងហិ ចុះអាណាចូលអត់មានអោយគេដឹងខ្លួនអញ្ចឹង តែម៉ែក៏អញ្ចឹងដែរ តែមានគេ ចូលស្ដីកូនអត់អោយមានម្ចាស់ខ្លួនគេដឹងទេ!!ហើយដល់តែឯងដើរបន្តិចសុទ្ធតែប្រចណ្ឌ

ចេះមួយចេះមួយ ហើយញ៉ុមខឹងញ៉ុមប្រចោរ (ប្រហែលជាគាត់ចង់និយាយពីមុនពេលគាត់រៀបការ គាត់និយាយពីមុខទៅក្រោយពីក្រោយទៅមុខ)។ ហើយញ៉ុមទៀតញ៉ុមមើលគ្រូទៀត គ្រូទាយ ទៅមើលគ្រូ គ្រូហ្នឹងជិះផ្ទះញ៉ុមទៀតណាស់ គ្រូហា គ្រូមុខផ្ទះសាលារៀនហ្នឹងហាំ!! យាយយាយញ៉ូមចង់ដឹងមើលគ្រូបន្តិច ស្រាប់តែគ្រូហ្នឹងថាអញ្ចេក ហ៊ុមីនាងឯងគាត់ដឹងទៀត ហ៊ុមីនាងឯងមិនបាច់មើលទេ អាប្រុសហ្នឹងមករាល់ថ្ងៃហ្នឹងហិ !!ចំអាប្រុសហ្នឹងណាមករាល់ថ្ងៃញ៉ុម!! ហើយអ៊ំហ្នឹងគាត់អត់ដឹងទេគាត់អត់ដែលចេញក្រៅគាត់នៅតែក្នុងផ្ទះផ្ទះថ្មគាត់អត់ដឹងទេ តែគាត់ថាឃើញស្រមោលខ្ញុំ ពេលឃើញស្រមោលខ្ញុំដើរចូលភ្លាមគាត់ដឹងគាត់មើលដឹងភ្លាមតែម្តង!!ដឹងម៉ងចុះគាត់គ្រូគាត់ដឹងណាស់។កះចាំ!!ខះគាត់គ្រូគ្រូហ្នឹងគាត់ដឹងណាស់គ្រូគាត់ពូកែណាស់ !!ថាអញ្ចេកហ៊ុមីនាងឯងដឹងហើយមីនាងឯងមិនបាច់ចាំមើលទេមីនាងគ្រាន់តែអាប្រុសហ្នឹងចង់បានមីនាងឯងមែនហ្នឹង មីនាងឯងដឹងថាអាប្រុសហ្នឹងមករាល់ថ្ងៃ!! ហាំអាប្រុសណាមករាល់ថ្ងៃ ម៉េចអ៊ំញ៉ុមអត់ដឹងទេ ហ៊ុមីអូនឯងចង់ដឹងល្ងាចបន្តិចមកហើយ ដល់ពេលល្ងាចបន្តិចមក មែនដល់ពេលហ្នឹងអាមួយណាអាប៉ិមួយធ្វើទាហានហ្នឹង?អើរ!!អីអាប៉ិហ្នឹងចង់បានញ៉ុម មកច្រាស់បាយញ៉ុមរាល់ថ្ងៃចង់បានញ៉ុម។

ក៖ហើយអ៊ីចឹងក៏បានប៉ុន្មានខែក្រោយមកអ្នកមីងក៏បានរៀបការមានកូន៥នាក់អ្នកមីង ណោះ ពេលបន្ទាប់ពីរៀបការហើយ?

ខ៖ចាំ??

ក៖ មានកូន៥នាក់ណោះ?

ខ៖ មានអី?

ក៖ មានកូន៥នាក់មែនទេជាមួយប្ដីមុនហ្នឹង?

ខ៖ មានកូន៥នាក់ពេលបានប្ដីមុនហ្នឹង!!

ក៖ អ៊ីចឹងឈ្មោះអីគេខ្លះកូនទាំង៥នាក់ហ្នឹងមីងមើលប្រាប់បន្តិចមើល?

ខ៖ ឈ្មោះថា។

ក៖ ដឹងហើយប្ដីឈ្មោះថា ប៉ុន្ដែកូន៥នាក់ហ្នឹងបងគេឈ្មោះអី?

ខ៖ បងគេហេ?

ក៖ ហ្នឹងហើយ។

ខ៖ ឈ្មោះមិត្ត។

ក៖មិត្តហ្នឹងស្រីឬក៏ប្រុស?

ខ៖ មិត្តហ្នឹងប្រុស។

ក៖ កូនស្រីប៉ុន្មានប្រុសប៉ុន្មាន?

ខ៖ ស្រី៣ប្រុស២។

ក៖អូខេ ដំបូងឈ្មោះមិត្ត ចុះទីពីរ?

ខ៖ ប្រុសមួយទៀតបន្ទាប់ឈ្មោះម៉ាប់។

ក៖អាម៉ាប់!!ខ៖ចាំ!!ក៖ទីបី?

ខ៖ បន្ទាប់មួយទៀតឈ្មោះស្នា។

ក៖ មួយទៀត?

ខ៖ ស្នាស្រី។ក៖ចាំ!!ខ៖ បន្ទាប់មួយទៀតឈ្មោះវណ្ណាដែលអង្គុយនេះ ដែលបងឯងថាស្អាតហ្នឹងណាស់!!ក៖ចាំ!!ខ៖មួយទៀតឈ្មោះណែត។

ក៖ឈ្មោះណែតហេ?ខ៖ ចាំ!!ក៖ត្រកូលពួកគាត់អីគេដែរ?

ខ៖ ចា??

ក៖ ដាក់ឈ្មោះត្រកូលថាទាំងអស់មែនទេ?

ខ៖ គាត់កងកូនញ៉ូមហ្នឹង!!

ក៖ចាំហ្នឹងហើយ!!(សួរទៅកូន)អូនត្រកូលអីចូលរៀន?

កូន៖ញ៉ុមមែន?ក៖ចាំ!!ខ៖ញ៉ុមពៅស្រីណែត។ក៖ហ្អ៎!!!

ខ៖ នេះកូននេះពៅគេហើយ ពៅគេនេះចាំ!!

ក៖ ហ្អ៎!!អ៊ីចឹងប្ដីក្រោយឬក៏ប្ដីមុន?

ខ៖ ប្ដីមុន។

ក៖ប្ដីមុនទេហេ?

ខ៖ ចា៎!!

ក៖អញ្ចឹងដាក់ពៅទាំងអស់គ្នា!!

ខ៖ ចា៎ ៥នាក់ហ្នឹងសុទ្ធតែពៅហើយកូនខ្ញុំកូនទាំង៥នាក់ហ្នឹងហា៎!!

ក៖ អញ្ចឹងមីងកូនទាំង៥នាក់ហ្នឹងអោយទៅរៀនទាំងអស់គ្នាតើមែនទេ?

ខ៖ ៥នាក់នៅញ៉ុមទាំងអស់ នៅញ៉ុមទាំងអស់។ក៖ចា៎!!ខ៖ ហើយមានតែមីពៅហ្នឹងនៅ

ជាប់ញ៉ុម ក្រៅពីហ្នឹងមានប្ដីមានប្រពន្ធអស់ហើយ តែនៅបែកបែកគ្នា ដែលញ៉ុមប្រាប់បង ឯងថាបងឯងអោយកន្ទ្បែងហ្នឹងណាស់!!!ក៖ចាំ!!ខ៖ ផ្ទះវានៅនេះ ផ្ទះវានៅនេះ។ក៖ចាំ!! ខ៖ នៅជិតផ្ទះបងញ៉ុមនេះ!!

ក៖ចាំតែចង់និយាយថាពួកគាត់បានរៀនអោយអីអត់ អោយទៅរៀនអោយទៅសាលាអីដែរ មែនទេ?សាលារៀនបានអោយទៅដែរតើអូនហោ?

កូន៖ សួរអោយទៅរៀនអត់(គាត់សួរប្រាប់ម្ដាយរបស់គាត់)

ខ៖ អត់ផងហ្នឹង។

ក៖ ចុះមីអូនទៅរៀនតើហី?

ខ៖ នេះទឹមអោយទឹមចូល ទឹមអោយទឹមចូល!!ក៖ហ្ហ៎!!ខ៖វាទឹមតែចូលតើនេះ!!ទឹមតែចូល ពីរឆ្នាំហ្នឹងណាស់ព្រោះអីកាលពេលវានៅទូចៗញ៉ុមទៅណាតាមទៅរតនៈគិរីទៅអីអ៊ីចឹងទៅ

យកវាទៅតាមទឹមតែឆ្នាំហ្នឹងនៅជាប់ ទឹមតែចូលតើទឹមតែចូលធំហើយទឹមតែថ្នាក់ទីមួយ

ហ៎!!

ក៖ ចាំអត់អីទេ កុំរៀនទៅ!!

ខ៖ តែគ្រាន់តែថ្នាក់ទីមួយតែគ្រាន់តែវាចេះ ចាំ!!

ក៖ ចាំអញ្ចឹងអ្នកមីងម៉េចបានជួបប្ដីទីពីរមកដឹងតែប្ដីពេលមុនស្លាប់ទៅមែនទេមីង?ហើយ

ម៉េចបានជួបប្ដីទីពីរមកលោកពូមិញហ្នឹងណាស់?

ខ៖ ម្នាក់ហ្នឹងទឹមតែស្គាល់គ្នាកាលពេលនៅរតនៈគិរី ចាំ!!

ក៖ ហ្អំអញ្ចឹងទឹមតែស្គាល់គ្នានៅរតនៈគិរីទេអញ្ចឹងហេ?

ខ៖ ចាំ!!

ក៖ ហើយម៉េចដែរបានស្រលាញ់គ្នា?

ខ៖ ចាំធ្លាប់ឃើញធ្លាប់ជិះឡានទៅជាមួយគ្នា ខ្ញុំអត់ចាប់អារម្មណ៍ស្គាល់គាត់ទេតែគាត់ គាត់ញ៉ុមថានៅព្រៃកប្បូរ ដំណាក់សង្កែហើយគាត់នៅព្រៃករាំងនេះ ដល់ពេលហើយដល់រតនៈគិរីហ្នឹងគាត់ឃើញញ៉ុមគាត់មេម៉ាយដែរ ដល់តែគាត់ឃើញញ៉ុមមកលេងសើចលេងសើចគាត់សុំស្រលាញ់ញ៉ុម ញ៉ុមអត់យក ញ៉ុមថាញ៉ុមឆ្អែតហើយញ៉ុមបានប្ដីមុនកូន៥ឆ្អែតហើយញ៉ុមលែងចង់បានហើយ ថាអញ្ចឹងហិថាលែងចង់បានហើយថាអញ្ចេកញ៉ុមស្អប់អាអ្នកផឹកស៊ីញ៉ុមអត់ចូលចិត្តទេ អ្នកផឹកស៊ី ហើយគាត់ថាហ៊ីញ៉ុមអត់ផឹកទេដល់ពេលមានប្រពន្ធញ៉ុម
ខំរកស៊ីចិញ្ចឹមប្រពន្ធកូនហើយ ហើយនិយាយអញ្ចេះៗ ហ៊ីអត់ផឹកហើយនិយាយមកជាមួយញ៉ុមធំក្លិនស្រា អាហ្នឹងញ៉ុមនៅម្នាក់ឯងញ៉ុមពិបាកចិត្តពេកចេះតែផឹកអោយមួយកែវមួយកែវទៅ ញ៉ុមមានដែលផឹកអីអោយណា តាមតូបតាមផ្ទះតាមអីណា តាមគេដូចគេដូចឯងឯងណា។

ក៖តែគាត់មានកូនដែរតើហី?

ខ៖ ចា៎??

ក៖ គាត់មានកូនទេប្ដីរបស់មីង?

ខ៖ គាត់គាត់មានកូន កូនគាត់នៅកំពង់ស្ពឺហ្អ៎!!ញ៉ុមអត់ដែលស្គាល់ផង!!ក៖ហ្អ៎!!ខ៖កូនគាត់កូន២ !!ក៖ចា៎!!ខ៖ កំពង់ស្ពឺញ៉ុមអត់ដែលទៅទេ អត់ដែលទៅយូរហើយណាស់ប្រហែលយូរឆ្នាំហើយ។ក៖ចា៎!!ខ៖ចា៎!!

ក៖ ហើយដល់ពេលហើយបានជាព្រមស្រលាញ់គាត់អញ្ចឹងទៅអ្នកមីងណោះ?

ខ៖ ចា៎ ដល់ពេលហើយគាត់សុំស្រលាញ់ដល់ពេលយូរៗទៅបានស្រលាញ់គាត់យកជាប់គ្នាទៅ ដល់ពេលមករៀបរៀបឯណោះ ហើយនៅស្រុកហ្នឹងគេនៅរតនៈគិរីគេស្រលាញ់គ្នា

គេប្រាប់មេ ប្រាប់មេមេរៀបការអោយណាស់ ហើយគាតង់អត់ហ៊ានប្រាប់ទេ អត់ហ៊ានប្រាប់ ឯងការនៅផ្ទះរបស់ មករៀបផ្ទះឯងទៅ គេការគ្រប់គ្នាសុទ្ធតែគេស្រលាញ់គ្នានៅឯណាឯណីណោះគេស្រលាញ់គ្នាប្រាប់មេមេរៀបការអោយ ហើយឯងនៅហ្នឹងមករាប់ឆ្នាំហើយមកមុនគេទៀតហើយដល់អត់ហ៊ានប្រាប់មេ!!ក៖ចាំ!ខ៖ ហើយហើយគេនិយាយគ្រប់គ្នា បងមួយរាប់អានញ៉ុមគាត់និយាយថាអញ្ចេកអាវីឯងទៅនិយាយប្រាប់មេប្រាប់អ៊ំលីថាញ៉ុមអើរញ៉ុមពីរនាក់ហ្នឹងស្រលាញ់គ្នាយូរណាស់ហើយអ៊ំញ៉ុមពួកចាស់ផងស្រលាញ់គ្នាយូរណាស់ហើយ ឥឡូវអត់មានលុយកាក់អីទេអ៊ំជួយញ៉ុមផង កុំអីអ៊ំជួយបាត់ហើយ ហើយអ៊ំលីហ្នឹងហៅគេទៅណាទៅតែជាមួយគាត់ទេ អ៊ំលីហ្នឹងហៅតែគេហ្នឹងទៅទេ ហើយគាត់អត់ហ៊ានទេ

ហើយគាត់ដើរតែជាមួយអ៊ំលីខ្លាចដែរអត់ទៅ ញ៉ុមអត់ហ៊ាន ហើយគេទឹមតែមក ទឹមតែមកថ្មីថ្មោងបានបានមួយខែពីរគេគេបានគ្នាស្រលាញ់គ្នាឯណាឯណី ទឹមតែមកធ្វើការនៅទីហ្នឹងបានកន្លះខែមួយខែ គេសុំអ៊ំនេះស្នើរអ៊ំដើម្បីរៀបការហើយគេការអោយ ប៉ុនឯងពួកចាស់អត់សុំ អ៊ីចឹងអត់ទៅ។

ក៖ អញ្ចឹងក៏បានរៀបការជាមួយគ្នាមកអ្នកមីងណោះ?ហើយមានកូនទេ ពេលរៀបការ

ហើយជាមួយលោកពូ?និយាយថាមានកូនដែរឬអត់ពេលមានប្ដីក្រោយនេះហិ?

ខ៖ ហ្នឹងប្ដីក្រោយ។

ក៖ មានកូនឬក៏អត់?

ខ៖ អត់មានទេ។

ក៖អត់មានទេហេ?

ខ៖ ញ៉ុមអត់អោយមាន។

ក៖ ម៉េចអ៊ីចឹងវិញ?

ខ៖ ញ៉ុមអត់អោយមាន។

កៈ អញ្ចឹងមានកូន៥នាក់ហើយ?

ខៈ ចាំមានកូន៥នាក់ហើយមានប្តីប្រពន្ធកូន ប្តីមុនហ្នឹងប្តីក្រោយអត់។កៈចាំ!!ខៈ សុំញ៉ុម ដែរថាអោយមានតែញ៉ុមអត់អោយមាន អត់អោយមានឃើញពិបាកអត់អោយមានមិនដូចប្តីញ៉ុមមុន!!ទឹមតែឥឡូវហ្នឹងទេ ទឹមតែឥឡូវហ្នឹងទេស្រួល!!កៈចាំ!!ខៈក៏មើលទៅពិបាកញ៉ុមអត់អោយ ញ៉ុមយ៉ាប់ណាស់ញ៉ុមមើលលំបាកមិនមែនដូចប្តីញ៉ុមមុនទេ ប្តីញ៉ុមមុនថិតថេរណាស់ ប្រពន្ធកូនខ្ចីមួយៗបាយទឹកស៊ីមួយថ្ងៃ៣ដង៤ដងហ្នំ!! ប៉ុន្តែមើលគាត់ខុសគ្នា ញ៉ុមមើលទៅខ្លាចពិបាកខ្លាចខ្លួនញ៉ុមពីបាកណាស់ ញ៉ុមអត់អោយមានទៅ មានដែរញ៉ុមប្រាប់ ញ៉ុមរាល់ថ្ងៃមាន ប៉ុន្តែញ៉ុមលើកកូនកៅស៊ូអោយទៅខ្លួនឯងតែម្តង ញ៉ុមអត់អោយមានទេ ដល់ហើយញ៉ុមនិយាយប្រាប់គាត់ថា ញ៉ុមានដែរតែញ៉ុមលើកកូនកៅស៊ូ ខឹងខ្ញុំ!!

កៈ អីគេលើកកូនកៅស៊ូធ្វើអីគេ?

ខ៖ កូនកៅស៊ូ អាកូនកៅស៊ូនោះ!!នោះធ្វើការកូនកៅស៊ូធ្វើការកូនស៊ូគេមិនដាក់ដាំ!!ក៖ ចាំ!!ខ៖ គេធ្វើតែមួយរងមួយរងញ៉ុមមួយថ្ងៃបាន៤ ទៅ៥រងណាស់ ញ៉ុមលើកហាំ រងប្រវែង ប្រវែងនេះដល់សសរហ្នំ!!!

ក៖ លើកទៅកុំអោយមានកូនហេ?

ខ៖ លើកបង្វិលកូន លើកបង្វិលវា កាលពេលមុនវាដាក់ដាំអញ្ចេះដល់ពេលកូនជិតលើកគេ បង្វិលកូនវា បង្វិលកូនវាយើងជីកៗគាស់ៗយកមុខវាបង្វិលៗដាក់ដាក់អាខ្សែងខ្សែងអោយ ទល់គ្នាគេបង្វិលញ៉ុមលើកមួយថ្ងៃ៣ ៤ ៥រងក្នុងមួយថ្ងៃគេលើកបានតែមួយថ្ងៃ២រងទេញ៉ុម លើកបាន ៤ ៥រងណាស់។

ក៖ ហើយអ៊ីចឹងក៏របូតកូនហ្នឹងទៅ?

ខ៖លើកមកបាត់ទៅ លើកមកបាត់ទៅ ដល់ពេលញ៉ុមប្រាប់គាត់គាត់ខឹងខ្ញុំ ខ្ញុំប្រាប់ខ្ញុំអត់ ទុកទេ ញ៉ុមប្រាប់ ញ៉ុមនៅពីក្មេងញ៉ុមស្អាតណាស់!!

កៈហ្នឹងហើយ។

ខៈ ញ៉ុមប៉ុនផឹកពេក។

កៈ ចំណាស់ហើយក៏នៅតែឡូយផង!!អូខេ អញ្ចឹងអ្នកមីងសំរាប់ជំនាន់លន់ នល់វិញ ចូល

ដល់ជីវិតសង្គ្រាមម្តងហា៎អ្នកមីង អាជំនាន់ទំលាក់គ្រាប់បែកនោះមីងទាន់ទេ?

ខៈ ហេអាហ្នឹងទំលាក់គ្រាប់បែកញ៉ុមអត់ទាន់ទេ។

កៈ ពេលលន់ នល់ហា៎ មីងកើតមុនលន់ នល់ទេតើ!!

ខៈ ជំនាន់ លន់ នល់ ញ៉ុមនៅទូចៗដែរ ញ៉ុមនៅប៉ុនៗវាហ្នឹង!!

កៈហើយពេលហ្នឹងម៉េចដែររត់អី?

ខ៖ កាលហ្នឹងរត់ដែររត់ចូលត្រង់សេអីដែរហ្នឹងហា៎!!

ក៖ ម៉េចវិញទៅ?

ខ៖ វាមានម៉េចញ៉ុមរត់ចូលទៅក្នុងត្រង់សេញ៉ុមខ្លាចមិនដឹងរត់ចូលទៅណាទៅណីទៅរត់ទៅវត្តគោករមៀតគោកអីទៅ ញ៉ុមចូលត្រង់សេញ៉ុមឃើញពួកទាហានពាក់មួកដែកខ្ញុំខ្លាចសឹងអីហើយ ដល់ពេលហ្នឹងខ្លាចទាហានតែប្ដីឯងធ្វើទាហានបានប្ដីធ្វើទាហានញ៉ុមខ្លាចទាហានទៀតណាស់!!ធ្លាប់ឃើញកាលពេលជំនាន់ប៉ុនៗវា(ប៉ុនកូនស្រីនៅជិតកន្លែងសំភាសន៍ហ្នឹងអាយុ៨ឆ្នាំ)ទៅឃើញអាពួកនេពាក់មួកដែកហ្នឹង!!ពួកខ្មែរយើងតែពាក់មួកដែកហ្នឹង!!ក៖ចា៎!!ខ៖ ចូលក្នុងត្រង់សេអញ្ចឹងវាដើរកាត់ត្រង់សេទៅខ្លាចសឹងងាប់ ហើយដល់ពេលបែកលន់ នល់ហើយមកតាមស្រុក ស្រុកស្រួលប្រួលហើយមកតាមស្រុក ស្រុកស្រួលប្រួលហើយរត់មកតាមស្រុកតាមទេសនៅឃើញទាហានខ្លាច ដល់ពេលប្ដីឯងធ្វើទាហានរឹតតែខ្លាចទៀតឃើញប្ដីធ្វើទាហានខ្លាចទៀត ខ្លាចដែរណាស់ គ្រាប់ផើរៗៗរត់ពេញណាពេញណីដាក់អីវ៉ាន់ទៀតរត់ទៅវត្តគោករមៀត។

ក៖

ហើយចុះមានដែលមានបងប្អូនឬក៏សាច់ញាតិណាដែរគាត់ស្លាប់ដោយសារគេទំលាក់គ្រាប់បែកត្រូវអីអត់មីង?

ខ៖ មានដែរទំលាក់គ្រាប់បែកចំ មានទំលាក់គ្រាប់បែកនេះដាច់ស្ពាន ដាច់ស្ពានហ្នឹង!!ក៖ចាំ!!ខ៖ អាហ្នឹងពេលហ្នឹងម៉ែញុំមកំពង់តែចាក់បាញ់ឆេងគេបោកដាច់ស្ពានហ្នឹង ស្ពានហ្នឹងមិនដាច់អាស្ពានព្រែកហូរហ្នឹង!!ក៖ហ៊ឺៗ!!ខ៖ គេមិនបោកគ្រាប់បែកមិនបោកផ្តាច់ស្ពាន ទំលាក់គ្រាប់ផ្តាច់ស្ពានទៅកុំអោយប្រជាជនយើងឆ្លងទៅណាឆ្លងទៅណាអោយងាប់មួយកន្លែងទៅៗ!!ដល់ហើយស្ពានហ្នឹងអត់ដាច់ដាច់តែមួយចំហៀងហ្នឹង ហើយដល់ពេលស្រុកស្រួលប្រួលគេមិនគេមិនធ្វើស្ពានហ្នឹង!!ក៖ចាំ!!ខ៖ គេមិនធ្វើឡើងស្អាតស្ពានហ្នឹង!!ម៉ែញុំកំពុងតែចាក់បាញ់ឆេងម៉ោងមួយម៉ោង២គេបោកគ្រាប់បែក!!ក៖អូយ!!ខ៖ បោកគ្រាប់បែកផ្អើល ថាបោកដាច់ស្ពានអត់អោយប្រជាជនហ្នឹងឆ្លងបានទេ អោយប្រជាជននៅកកមួយកន្លែងអោយងាប់ហាំ ចង់អោយកកកុញផ្តុំគ្នាអោយងាប់អ៊ីចឹងហិ!! ដល់តែហើយផប្រជាជនចេះតែទៅទៅក្រោមៗៗទៅទៅរហូតទៅ ទៅស្ពានហ្នឹងយើងធ្វើតាំងពីយូរហើយទៅនោះ!!

ក៖ចាំ!!ខ៖ អាស្ពានព្រែកហូរហ្នឹង។

ក៖ តែឥឡូវគេរើចោល។

ខ៖ពេលហ្នឹងញ៉ុមនៅទូចៗដែរហ្នឹង!!ហើយដល់ពេលហើយរត់ទៅណោះ ទៅក្រោម គេបោកគ្រាប់បែកអ៊ីចឹងគេរត់ទៅក្រោមអីទៅកន្លែងអីតាអាត់ទៅអីទៅព្រែកហូរនោះ តាអាត់អាចមន៍កុកនោះ!!ក៖ចាំ!!ខ៖ នៅព្រែកហូរលិចដាំពោតដាំអីនោះ!! ហ្នឹងទៅហ្នឹងទៅម៉ុំហ្នឹងទៅហ្នឹងទៅសម្ងំហ្នឹងទៅពួននៅដើមសង្កែទៅពួននៅកន្លែងព្រៃហ្នឹង ដើមគរទីនេះហ្នឹង

ខាងក្រោមសុទ្ធតែសំបូរដើមគរ ទៅហ្នឹងទៅហ្នឹងដើមគរគេមួយជួរមួយជួរឥឡូវខ្ទេចខ្ទីអស់ហើយ គេមកដាំធ្វើអីហ្នឹង!!

ក៖ ចាំអញ្ចឹងអ្នកមីងពេលចូលដល់ជំនាន់ប៉ុល ពតណាស់ជីវិតអ្នកមីងម៉េចដែរ?

ខ៖ ហើយបងញ៉ុមហើយគេមួយជិតខាងគេខ្លាចហាំ ចោលគោចោលអីស្រាប់ហើយបង ពូ

ញ៉ុមពូជូន គាត់ខ្លាចគ្រាប់ គាត់ចោលអីវ៉ាន់នៅណោះគាត់រត់រកតែព្រះអាយូសចោលស្អីៗ នៅដំណាក់សង្កែហ្នឹងបងញ៉ុមថាអញ្ចេកអត់ហ៊ានទៅយកទេ អត់ទៅយកបងញ៉ុមគាត់យក អោយ គាត់ថាហ៊ីឃើញគ្រាប់រហូតបាញ់ផែវៗគាត់អត់ហ៊ាន បងខ្ញុំគាត់ធ្លាប់តស៊ូគាត់ធ្លាប់ ធ្វើទាហានហ្នឹង បងញ៉ុមបងថ្លៃញ៉ុមក៏ទៅយកអោយមក ដល់ហើយយកអោយមក ដល់ ហើយហ៊ីហ្អែងកុំទៅអី!!ព្រោះអីគ្រាប់បាញ់មកផែវៗ ថាហេយើងខ្លាចអី គេបាញ់ទៅឯណា ឯណីណោះ បាញ់ឆ្លងឆ្លើយគ្នាឯណាឯណីណោះសោះមិនមែនបាញ់មកពួកយើងឯណា!! ហ៊ីបាញ់ឆ្លងឆ្លើយគ្នាឯណាខ្លាច បងញ៉ុមទៅយកអោយមកបររទេះទៅក្រោម គាត់រត់ចោល គាត់រត់រកតែព្រះអាយូសតែខ្លួនគាត់ គាត់ខ្លាច!!ក៖ចា៎!!ខ៖ ចុះគាត់អ្នកធ្វើទាហានគាត់ ខ្លាចអី!!តែប្តីញ៉ុមធ្វើទាហានហ្នឹងហា៎គេឡើងអ៊ីគាត់ចុះមាសហា៎ ឪពុកគាត់ធ្វើគ្រូណាស់ គេ បញ្ចុះមាសនៅក្នុងហ្នឹង៥ហ៊ុនណាស់បញ្ចុះសាច់មាសណាស់ ចុះយើងទៅឡើងអ៊ីទៅឡើង អីទៅ ពេលគេបាញ់ពេលគេផ្លោងអីទៅ ពេលអំបែងខ្ទាត់ចេញអំបែងអត់មានចូលសាច់ទេ!! ក៖ហ្ហ៎!!!ខ៖ ហើយសមប្តីញ៉ុមហ្នឹងគាត់ធ្វើ ធ្វើមេគ្រូស្នេហ៍!!ក៖ហ្ហ៎!!ខ៖ ធ្វើមេគ្រូស្នេហ៍ ហើយដល់ពេលមក ដល់ពេលមកចាប់មកឪគាត់ ឪពុកគាត់ក៏គ្រូម៉ែក៏គ្រូ ម៉ែខាងម្តាយគាត់ ហ្នឹងក៏គ្រូទៀតគ្រូទាំងអស់ កាន់ជាប់គ្រូ គ្រូពូកែពូកែណាស់!!ក៖ចា៎!!ខ៖ ហើយដល់មក គាត់គ្រូដែរគ្រូអត់មានមើលអីគេទេ គ្រូស្នេហ៍គ្រូថាគេមានប្តីមានប្រពន្ធអីអញ្ចឹង ចង់បែក

បាក់ចង់មានប្ដីអីអ៊ីចឹង មានប្រពន្ធចុងមានប្រពន្ធដើមអីអញ្ចឹងគេអោយធ្វើអីអញ្ចឹង មួយក្លង មិនតិចទេ មួយក្លង៥០រៀលអីហ្នឹ!! ហើយបងញ៉ុមគាត់ធ្វើអោយ គាត់ធ្វើការនៅរោងគាត់ ធ្វើការនៅភ្នំពេញគេអោយធ្វើអោយគាត់អត់ធ្វើអោយទេ គាត់ថាអើយអាកុំធ្វើអញ្ចឹងហ៎ា កុំ ធ្វើបាបហ៎ា កុំធ្វើបាបគ្នា អញប្រពន្ធគេប្រពន្ធឯង ចិញ្ចឹមប្រពន្ធអញមានប្រពន្ធតែមួយអញ រកស៊ីចិញ្ចឹមងាប់នឹងដៃអញរស់នឹងដៃអញហ្នឹង អញធ្វើអញ្ចឹងអញអត់ចេះមានប្រពន្ធមាន ស្រីមានអី អត់ចេះមានស្រីមានញីអីទេ ហ្អែងញ៉ុមមានចេះមានស្រីមានញីអី មិនបាច់ធ្វើ ស្នេហ៍ដាក់អីដាក់អីគ្នាចង់យកប្រពន្ធចុងអីទេ យកទៅបើអញ្ចឹងហ្អែងមានលុយមានកាក់អី អោយទៅ ថាអញ្ចឹងហិ ហេ!ចង់ដាច់គ្នាតែម្ដងចង់ដាច់គ្នាចង់បានប្រពន្ធផ្សេង ចុះវាធ្វើការ វាធ្វើយូរៗទៅគេអ្នកថែទាំណោះហើយប្រពន្ធនៅរហូតដល់ណាណើណោះ កន្លះខែមួយខែ មកម្ដងប្រពន្ធដើឡើងប៉ោងមុខអស់អត់មានលុយអោយ កន្លះខែអីមកម្ដងៗ!!ក៖ច៎ា!!ខ៖ចុះ បើវាប្រគល់អោយអាប្រពន្ធស្រីអស់ហើយ បាត់មុខបាត់មាត់យូរកន្លះខែអីបានលុយមក ១០០០០០ អីវ៉ាន់អញបានស៊ីចាយអី អញជំពាក់គេវន្តករមកប្រពន្ធដើឡើងពោងមុខ។

ក៖ ច៎ាអញ្ចឹងអ្នកមីងចូលដល់ជំនាន់ប៉ុល ពតជីវិតរបស់អ្នកមីងម៉េចដែរ ពេលមុនដូចប្រាប់ញ៉ុមបាននិយាយបន្តិចបន្តួចពីជីវិតរបស់អ្នកមីង

និយាយរៀបរាប់អោយបានក្បោះក្បាយតិចមើល??ពេលជំនាន់ប៉ុល ពតហ៎!!គេធ្វើបាបមីងទេ?

ខ៖ ពួកណា?

ក៖ ពួកប៉ុល ពតណាស់!!ពេលជំនាន់សង្គ្រាមហ្ន៎!!

ខ៖ អត់មានធ្វើអីទេ ពីដើមអត់មានធ្វើអីទេ អាចដើរដើរអញ្ចឹងវាមិនធ្វើអីទេ វាគិតតែពីសើច អញ្ចឹងទៅណាស់ វាអត់គិតមានធ្វើអីយើងទេ!!

ក៖ ម៉េចអញ្ចឹងវិញ!! ហើយមីងធ្វើការអីគេពេលនៅក្នុងជំនាន់ប៉ុល ពតហ៎?

ខ៖ វាដូចថាពួកខ្លះដូចតែជាយើងដែរ វាដើរឡើងអញ្ចេះវាដើរឡើងទៅ!!ឡើងៗទៅលើអញ្ចឹងទៅ ហើយឯងខ្លាចអីជំនាន់ហ្នឹងគេមានធ្វើអី!!ហើយដើរគ្រាន់តែក្រឡេកមើលឯងឃើញសើចដាក់អញ្ចឹង វាសើចដាក់យើយឯងអញ្ចឹងវាសើចមកអញ្ចឹង!!

ក៖ មីងពេលប៉ុល ពតនៅណាវិញសង្គ្រាមហ្នុំ!!បន្ទាប់ពេលលន់ នល់ហើយគេបាញ់គ្នា?

ខ៖ សង្គ្រាមអាណាដឹងនៅណាមិនដឹងដែរ!!

ក៖ មីងនៅដំណាក់សង្កែហ្នឹងឬក៏គេជំលៀសទៅឯណា?

ខ៖ នៅដំណាក់សង្កែហ្នឹងដែរ តែមិនដឹងដំណាក់សង្កែមុំណាមិនដែលស្គាល់ វាភ្លេងអស់វាមិនដឹងមុំដំណាក់សង្កែដែរ!!ក៖ហ្នុំ!!ខ៖វាដឹងថានៅមុំដំណាក់សង្កែប៉ុន្តែមិនដឹងមុំទីណាណាស់ !!

ក៖ ហ្នុំអញ្ចឹងហេ?

ខ៖ ចាំ!!

ក៖អញ្ចឹងពេលហ្នឹងមីងបងប្អូនមីងមានស្លាប់ដោយសារសង្គ្រាមប៉ុល ពតទេ?អត់មានទេហេ?

ខ៖ អត់មានទេ!!

ក៖ហ្អូមីងដែលឃើញសាកសពគេយកមនុស្សទៅសម្លាប់ចោលដែរឬក៏អត់?

ខ៖ អត់ អត់ទេ!!អត់មានទេ តែទៅទៅទាំងអស់គ្នាតែម្តងហ្នឹង!!ដូចថាយើងដើរតាមពួកយើងដើរតាមពួកគាត់អញ្ចឹងទៅទាំងអស់គ្នាដើរទៅអញ្ចឹងតែម្តង ដើរអោយឃើញអីណាអត់ឃើញអីគេទេ!!តែដល់ថាឃើញដែរថាពួកគ្នាឯង។

ក៖ម៉េចវិញទៅមីង?

ខ៖ អាពួកគ្នាឯងមិនមែនពួកគ្នាគេ បើថាគេទឹមតែជំលៀសមកអញ្ចឹងវាទៅរកទៅរកពួកគេអញ្ចឹងទៅណាស់ ពួកឯងពួកអាធ្មេញខ្មៅពួកយៀកកុងអីណោះ !!អានេះបែបទាហានគ្នាឯង

ហ្នឹងណាស់ បែបទាហានគ្នាឯង ខ្មែរគ្នាឯងហ្នឹងណាស់ ហើយដល់ពេលរត់ទៅទៅទាំងអស់គ្នាវាដើរតាមពួកឯងដែរហ្នឹងទៅអញ្ចឹងសទៅក្រោមទៅអញ្ចឹងអញ្ចឹងទៅ ចាំ!!

ក៖ មីងហូបម៉េចដែរហូបបាយហូបអីណាស់ គេអោយហូបច្រើនឬក៏ពិបាកអីទេ?

ខ៖ បាយយើងដាំហូបដាំហូបខ្លួនយើងដាំ ដល់កន្លែងណាស្ងាត់អញ្ចឹងទៅយើងឈប់ដាំអីអញ្ចឹងស៊ីទៅ កាត់គ្រាប់កាត់អីយើងដាំបាយស៊ីទៅ ដល់ពេលស៊ីហើយអញ្ចឹងយើងចាប់ផ្តើមទៅទៀតទៅ!! ដល់ពេលស៊ីបាយហើយអីអញ្ចឹងៗលឺស្គរសំលេងគេថា ហ្នុំគេអោយជំលៀសទៅទៀតហើយអោយទៅទៀតហើយទៅខំរៀបចំដាក់លើរទេះដាក់លើអីអញ្ចឹងណាស់ទៅទៀតទៅចេះតែទៅទៅទៅដល់ណាចេះតែទៅទៅណាស់ ទៅដល់កន្លែងណាស្ងាត់យើងដាក់ទៅនៅទីហ្នឹងទៀតទៅទីហ្នឹងទៅ ទៅហ្នឹងដល់ណាដល់យប់ កន្លែងណាដល់យប់ហើយដេកទីហ្នឹងទៅក្រាលកន្ទេលក្រាលអីអញ្ចឹងទៅ!! មានព្រៃមានអីយើងក្រាលកន្ទេលអីនៅទីហ្នឹងទៅ!! ព្រលឹមឡើងឮស្គរថាគេនិយាយថាពីណាពីណីមកនឹងគេហ្នឹងមកញ៉ុមថាដូចមានតេរអ្វីអីអញ្ចឹងៗទៅណាស់ ហើយគេហ្នុំនិយាយថាអោយជំលៀសទៅណាទៅណីទៀត ទៅទៀតយើងទៅមុខទៀតទៅអញ្ចឹងណាស់ ហ្នឹងហើយទៅមុខទៀតទំរាំដល់

ពេលនៅដល់ពេលនៅយូរយូរទៅដល់ពេលសុខសាន្តត្រាណហ្នុំគេថាស្រុកនៅទីណាទីណី អោយមកនៅតាមស្រុកតាមទេសតាមស្រុកភូមិវិញ យើងមកតាមភូមិយើងមក!!

ក៖ អញ្ចឹងមឹងស្រួលដែរនៅជំនាន់ប៉ុលពត ដោយសារធម្មតាគេពិបាកខ្លាំងណាស់!!!គេមានពួកហ្នឹងគេមានតែពួកយើងនិយាយអីស្រួលមិនស្រួលគេយកយើងទៅសម្លាប់ចោលហ្នុំ!!

ខ៖ អាហ្នឹងខ្ញុំអត់ដែលឃើញជួបឃើញអីនៅឯណាទេ ថាខ្ញុំឃើញគេថាពួកគេពួកអីថាញ៉ុមតាមពួកញ៉ូមតាមមើលទៅឃើញតាមមួយដំនើរអ៊ីចឹងណាស់ ពួកគេខ្លះពិបាកដែរ ខ្លះយំរញ៉ៀវរញ៉ាកអីអញ្ចឹងទៅ ដាក់រទេះដាក់អីទៅយំរញ៉ៀវរញ៉ាកខ្លះពោះធំពោះអីអញ្ចឹងទៅហើយថា ហើយថាដូចថាស្រុករត់អញ្ចឹងទៅអូន បានអ្នកណាពោះធំពោះអីអញ្ចឹងឈឺពោះអីអញ្ចឹងៗមិនដឹងថាកើតណាកើតណីអញ្ចឹងទៅ!!ហើយខ្លះទៅ
ហើយថាអត់ដែលឃើញសម្លាប់ណាសម្លាប់អីទេ
ដូចថាមើលឃើញគេដូចពិបាកខ្លះកូនចៅយំរញ៉ៀវរញ៉ាកអត់អីស៊ីអត់អីអញ្ចឹងទៅណាស់!!

ក៖ ហ្អ៎តែម្ដាយរបស់អ្នកមីងហើយនឹងឪពុកហ្នឹងទៅណាខ្លះទៅ?

ខ៖ មិនដឹងនៅឯណានៅឯណីបើខ្ញុំចេះតែរត់ទៅខ្ញុំអត់ស្គូវដែរស្គាល់ ញ៉ុមចេះតែរត់ទៅណាស់ ដល់រត់តាមផ្លូវចេះតែឃើញតាមផ្លូវអញ្ចឹងទៅណាស់ដើរ!!

ក៖ តែមីងនៅជាមួយម៉ែឪពេលហ្នឹង?

ខ៖ ញ៉ុមហេ?ក៖ ចា៎!!ខ៖ ញ៉ូមនៅតាមជាមួយម៉ែញ៉ុមនៅជាមួយម៉ែញ៉ុមដែរហ្នឹង!

ក៖ហ្អ៎ហ្នឹងហើយ!!

ខ៖នៅជាមួយម៉ែញ៉ុមទាំងអស់ តែគ្រាន់តែថាញ៉ុមកាលពេលរត់ទៅហ្នឹងរត់ហ្នឹងបែកពីបងញ៉ុមនៅនារីនៅព្រែកកំពឹសណាស់!!ក៖ចា៎!!ខ៖ ចា៎នៅទំរាំបានជួបជុំគ្នាទំរាំតែបានមូលគ្នា

អាមួយនៅធ្វើទាហាន អាមួយនៅកុមារនោះ បងប្រុសនោះនៅកុមារដែរតែនៅវាខុសគ្នា ទំរាំទៅជួបគ្នាណាណើណោះ ទំរាំបានមូលគ្នាកូនចៅទាំងអស់គ្នាមូលគ្នា មកនាំកូនចៅមក នៅទាំងអស់គ្នា!!អត់មានបែកទេ!!ចា៎ដល់ពេលហើយថាទៅជួបអ្នកណាហើយទៅជួបទៅ អាណាមក ហើយបងប្អូនអ្នកណាគេមកធ្វើទាហានអីគេធ្វើយុវនារីនោះ។ក៖ចា៎!!ខ៖ កុមារយុវនារីនោះថាមានឃើញកូនខ្ញុំអីអញ្ចឹងទៅ!!ថាណោះនៅមកតាមក្រោយណោះអោ យចំាគ្នាចំានៅឯណាឯណើញ៉ុមចំានៅហ្នឹងថ្នល់ចំានៅជុំគ្នាអញ្ចឹងហិ!!ហើយឈរចំាមួយទៀ តបានមកចំាជុំគ្នាជួបគ្នាទាំងអស់កូនចៅជួបគ្នាទាំងអស់ហ្នឹង!!!ក៖ចា៎!!ខ៖ ចា៎!!នៅជុំគ្នាទាំងអស់អត់មានបែកគ្នាទេ!!ក៖ចា៎!ខ៖ តែគ្រាន់តែថាខ្ញុំមើលគ្នាអញ្ចឹង!!តែគ្រាន់តែថាញ៉ុមរត់អញ្ចឹងឃើញគេអ្នក អ្នកដទៃផ្សេងទៀតគេពិបាកវេទនាអ៊ីចឹងមានកូនមានចៅអញ្ចឹងអាញ៉ែអាញាក់អញ្ចឹងណាស់ !!

ក៖ ហើយឃើញតាមផ្លូវ មានខ្មោចមានសាកសពអីវ៉ាន់អីអត់?

ខ៖អត់ទេអត់មានអីទេ។

ក៖ អញ្ចឹងមីងហេងហើយនៅក្នុងពេលជំនាន់ហ្នឹង!!អញ្ចឹងមីងពេលចប់ជំនាន់សង្គ្រាមមក

មីងរកស៊ីអីគេដែរជាមួយឪពុកម្តាយ?រកស៊ីអីគេធ្វើការអីគេ?

ខ៖បើញ៉ុមមិនសូវដឹងដែរ ញ៉ុមអត់សូវចាំ!!

ក៖ អត់សូវចាំហេ?

ខ៖ ញ៉ុមនៅទូចៗដែរញ៉ុមដូចអត់ដឹងដែរ។

ក៖ មីងពេលវេលាដែលពិបាកបំផុតក្នុងជីវិតរបស់អ្នកមីងហ៎ ពេលណាវិញ?ពេលពីបាក

ជាងគេហ៎?

ខ៖ ពិបាកជាងគេញ៉ុមអត់មានដែលពិបាកអីទេ ញ៉ូមរ់តទៅញ៉ុមអត់មានពិបាកអីផង។

ក៖ ហ្ហ៎អញ្ចឹងអត់ស្ទូវពិបាកចិត្តដែរហី?

ខ៖ ចា៎ៗ!!

ក៖ក្នុងជីវិត?

ខ៖អត់មានពិបាកទេធ្វើតាមដំនើរ។

ក៖ តែដល់ពេលអញ្ចេក ពេលប្ដីស្លាប់ចោលមឹងពិបាកទេ?ពេលមុន?

ខ៖ ញ៉ុមអត់ទេ ញ៉ុមម៉ាភ្នំអត់មានពិបាកអត់មានអីទេ ដូចថាប្ដីស្លាប់ទៅទៅញ៉ុមនៅកូន កូនទៅកូនរកស៊ីចិញ្ចឹមនៅជាមួយកូននៅមូលជាមួយគ្នា កូនធំៗគេរកការងារអីទៅ។ក៖ហ្ហ៎!!ខ៖ នៅជាមួយកូន ហើយដល់ពេលញ៉ុមមានប្ដីទៀតញ៉ុមនៅបែកគ្នាពីកូនបែកពីអីអញ្ចឹងទៅណាស់។

ក៖ ចាំហ្នឹងហើយ!!មើលសុំសួរបន្តិចមើល មើលបានដឹងអីគេខ្លះពីជីវិតរបស់ម៉ែប្រាប់តិច មើល!!ថាម៉ែជួបរឿងអីគេខ្លះនៅក្នុងជីវិតដែល ម៉ែមានដែលនិយាយប្រាប់អីអត់?

កូន៖អត់ផង!

ក៖ ម៉េចអត់ដឹងអញ្ចឹង?

កូនស្រី៖ព្រោះអីញ៉ុមនៅទូចញ៉ុមអត់សូវនៅជាមួយគាត់ ញ៉ុមនៅតែជាមួយអ៊ំហ្នឹង!!ក៖ហ្នំ!!

ខ៖ដល់ពេលញ៉ុមបែកមកវាទឹមតែកើតនេះហ្នឹងហេ។

កូន៖ញ៉ុមនៅជាមួយអ៊ំ ញ៉ុមបែកពីអ៊ំញ៉ុមញ៉ុមទៅធ្វើការរោងចក្រ ហើយបានញ៉ុមបានប្ដី ញ៉ុមទៅហ្នឹង ញ៉ុមអត់សូវបាននៅជាមួយគាត់ទេ!!ក៖ហ្នំ!!ខ៖កូនចៅនិយាយទៅកូនចៅ តាំងពីគាត់បានប្ដីក្រោយមកគឺកូនចៅអត់សូវនៅជុំគ្នាទេបែកគ្នាអស់រលីងហើយ!!ក៖ហ្នំ!!

ខ៖ តាំងពីប៉ាញ៉ុមស្លាប់មក តាំងពីប៉ាញ៉ុមស្លាប់ញ៉ូមទៅនៅជាមួយអ៊ំ។

ក៖ ចាំអញ្ចឹងរាល់ថ្ងៃនៅផ្ទះជាមួយគាត់ដែរអត់?

កូន៖ អត់ទេ ញ៉ុមនៅណោះផ្ទះញ៉ុមនៅណោះ។

ខ៖ ផ្ទះវានៅណោះ។

កូន៖ចាំតាំងពីប៉ាស្លាប់មកគឺនៅបែកគ្នាទាំងអស់ នៅជុំនេះនៅជុំតែមីនេះមួយទេ!!ក៖ចាំ!! ខ៖ញ៉ុមនៅជាមួយអ៊ំផ្សេងបងញ៉ុមនៅជាមួយអ៊ំផ្សេង!!ក៖ហ៊ឹៗ!!កូន៖ព្រោះអីតាំងពីប៉ាស្លាប់មក បានប៉ាបានអីគាត់ជាអ្នករកលុយមកចិញ្ចឹមកូន ដល់ពេលហើយនៅតែបងប្រុសញ៉ុមមួយបងប្រុសញ៉ុមបួសទៀត។

ក៖ ហ្អាគាត់ស្លាប់យូរនៅប៉ា?

កូន៖ ១០ឆ្នាំជាងហើយ!!

ក៖ហ្អយូរដែរហើយហ្នឹង អញ្ចឹងសុទ្ធនៅតែពេលហ្នឹងកូននៅទូចៗខ្លាំងណាស់?

កូន៖ចាំនៅទូចៗ។

ក៖ កាលពេលហ្នឹងគាត់ស្លាប់មូលហេតុអីគេ ភ្លេច ប្រាប់បន្តិចមើល ភ្លេចសួរមីង?

កូន៖ នេះគាត់ស្ទះខ្យល់ ដេកទៅដកដង្ហើមពាដងទៅម៉ែគាត់អត់ដឹងគាត់ស្មានតែដកដង្ហើមធម្មតាដល់ពេលព្រលឹមឡើងម៉ែគាត់ដាស់អោយប៉ាទៅស្រោចស្រូវគេហ្នុំដល់ពេលដាស់ទៅមិនដឹងថាដាច់ខ្យល់តាំងពីស្មើរម៉ាន!!អត់ដឹងផង!!ក៖ហ្នុំចាំ!!កូន៖ តែមុនពេលគាត់ស្លាប់គាត់កើតបូសនៅគៀនត្រចៀកនេះ!!ក៖ហ្នុំ!!កូន៖ចាំកើតបូសតែមិនដឹងថាស្លាប់មកពីមូលហេតុអី ព្រោះអីពេលល្ងាចគាត់ហូបកង្កែប។

ក៖ហ្អហ្នឹងហើយលីមីងនិយាយដែរ!!

កូន៖ចាំ!!មិនដឹងមកពីកង្កែបឬក៏ម៉េចដែរអត់ដឹងដែរ!!ពីព្រោះអីដកដង្ហើម៣ដងទៅម៉ែអត់ដឹងផងគាត់ស្មានតែដកដង្ហើមធម្មតា។ក៖ចាំ!!កូន៖ដល់តែភ្លឺព្រលឹមឡើងស្រាងៗបាន ដឹងគាត់ស្លាប់ស្លាប់តាំងពីស្ទើរម៉ាន់!!!

ក៖ ហើយចុះមីងម៉េចដែរអ្នកមីង ជាម្ដាយដ៏ល្អខ្លាំងអត់?ទោះជាមិនបានសូវនៅជាមួយគាត់តែស្រលាញ់ម្ដាយខ្លាំងណាស់ហេ?

កូន៖ ចាំ!!ស្រលាញ់។

ក៖ហ្នឹងហើយ អ៊ីចឹងរាល់ថ្ងៃបានកូនៗជួយទំនុកបំរុងគាត់ខ្លះៗដែរអត់?

កូន៖ចុះញ៉ុមរាល់ថ្ងៃអ៊ីចឹងញ៉ុមទៅលក់អញ្ចឹងទៅមកវិញទិញអីទិញអីអោយគាត់អញ្ចឹងទៅលុយអីគាត់ចាយអោយគាត់ចាយរាល់ថ្ងៃ។

ក៖ ហើយលក់អីគេដែរ?

កូន៖ ញុំមលក់ចានាឆ្នាំង។

ក៖ហ៊ូ!!

កូន៖ លក់គ្រឿងចានាឆ្នាំង។

ក៖នៅផ្សារដែរតើហី?

កូន៖លក់នៅផ្សារនៅតាមផ្សារ។

ក៖ ហ៊ូអញ្ចឹងបានកូនមានមុខរបរហើយអ្នកមីងណោះ!! អរគុណច្រើន អ៊ុចឹងអ្នកមីងមួយនេះគឺជាសំនួរមួយចុងក្រោយមានអីគេចង់ផ្ដែផ្ដាំកូនចៅខ្លះពេលថ្ងៃអនាគត់ទៅដែលពួកគាត់បានស្ដាប់សំលេងរបស់មីងហា មានអីចង់ប្រដៅកូនទេ?មើលនិយាយមួយម៉ាត់មក។

ខ៖ មានផ្តែផ្តាំអីអត់ទេ!!

ក៖ មើលនិយាយមកចង់អោយពួកគាត់ដើរលើផ្លូវម៉េចដែរ?

ខ៖ អត់មានផ្តែផ្តាំអីទេ។

កូន៖ម៉ែឯងហ៎!!និយាយម៉ែឯងចុងក្រោយចង់និយាយអីផ្តាំទុកខ្លះ?

ក៖ មានអារម្មណ៍អីចង់និយាយអីអត់?

ខ៖អត់មានអារម្មណ៍អីចង់និយាយអីទេ។

ក៖ ធ្វើអៀនអីណា!!មើលចង់ប្រដៅកូនថាអោយកូនដើរលើផ្លូវម៉េចដែរហើយជៀសផុតពីផ្លូវអាក្រក់ម៉េចដែរអ៊ីចឹងណាស់?

កូន៖គាត់អត់ស្ទូរដឹងគាត់អត់ស្ទូរចេះនិយាយ!!

ក៖ អត់ស្ទូរពូកែនិយាយហេ!!

ខ៖អត់មាន។

ក៖អញ្ចឹងអត់មានអីទៀតទេអ្នកមីងណេះ!!អញ្ចឹងអរគុណច្រើនអ្នកមីងសំរាប់ការសំភាសន៍នៅក្នុងថ្ងៃនេះហើយអ្វីទាំងអស់កូនចៅរបស់អ្នកមីងគាត់នឹងបានស្ដាប់អំពីជីវិតរបស់អ្នកមីងណាស់អ្នកមីង!!ចា៎អញ្ចឹងអរគុណច្រើនមីង។